BMI0071

# សម្ភាសជាមួយឈ្មោះ ហួន ហ៊ិន ភេទប្រុស អាយុ៦៦ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ «កងទ័ព»

មុខងារបច្ចុប្បន្នៈ «សមាជិកក្រុមប្រឹក្សាស្រុក»

ស្រុកកំណើតនៅៈ ភូមិនីពេជ្រ(ខ) ឃុំនីពេជ្រ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

សព្វថ្ងៃរស់នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០១ៈ៤៨ៈ០៨

៣៨ទំព័រ

ដានី ៖ បាទ!ដឹបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះអី?

ហ៊ិន ៖ ឈ្មោះ ហួន ហ៊ិន ។

ដានី ៖ បាទ!អ៊ំសព្វថ្ងៃអាយុប៉ុន្មានហើយ?

ហ៊ិន ៖ អ៊ើ!ឆ្នាំ១៩៤៥ អាយុ៦៦ហើយ

ដានី ៖ អ៊ំឈ្មោះ ហួន ហ៊ិន ហ្នឹងឈ្មោះពីកំណើតអត់មានដូរកាលបដិវត្តន៍ទេ?

ហ៊ិន ៖ ឈ្មោះពីកំណើត អត់មានដូរដោះអីទេ ។

ដានី ៖ បាទ!ភូមិនេះភូមិអីគេ?

ហ៊ិន ៖ ភូមិចំបក់ ឃុំបឹងប៉េង ស្រុកម៉ាឡៃ

ដានី ៖ បាទ!ចុះអ៊ំស្រីគាត់ឈ្មោះអីដែរ?

ហ៊ិន ៖ ម៉ក់ វ៉ូន

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ហ៊ិន ៖ អាយុ៥២ឆ្នាំ ។

ដានី ៖ គាត់អ្នកនៅណាដែរ ស្រុកកំណើតរបស់គាត់?

ហ៊ិន ៖ គាត់នៅ ពីមុនម៉ោស្រុកសេរីសោភ័ណ តែឥឡូវស្រុកព្រះនេត្រព្រះហើយ គេកាត់ឲ្យស្រុកព្រះនេត្រព្រះហើយ កាលពីយើងមិនទាន់បំបែកខេត្ត ។

ដានី ៖ បាទៗ ។

ហ៊ិន ៖ បាទ!នៅខេត្តបាត់ដំបង ស្រុកសេរីសោភ័ណ ប៉ុន្តែឥឡូវគេបំបែកហើយគាត់ តែការពិតគាត់ម៉ោពី៧៩ដែរ កាលបែកបាក់៧៩ក៏គាត់ម៉ោព្រំដែននេះ ។

ដានី ៖ បាទ!ចុះអ៊ំអ្នកស្រុកកំណើតនៅណាដែរ?

ហ៊ិន ៖ ខ្ញុំនៅកំពង់ធំ ។

ដានី ៖ កំពង់ធំភូមិអីគេ?

ហ៊ិន ៖ ភូមិនីពេជ្រ(ខ) ឃុំនីពេជ្រ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

ដានី ៖ ចុះអ៊ំសព្វថ្ងៃនេះអ៊ំមានតួនាទីអីដែរ?

ហ៊ិន ៖ ឥឡូវសមាជិកក្រុមប្រឹក្សាស្រុក កាលមុនសមាជិកក្រុមប្រឹក្សាឃុំបឹងប៉េង ។

ដានី ៖ អ៊ំចាប់ផ្ដើមសមាជិកក្រុមប្រឹក្សាស្រុកម៉ាឡៃពីឆ្នាំណាម៉ោ?

ហ៊ិន ៖ ឆ្នាំ២០០៨ មុនបោះឆ្នោត គិតទៅបាន១៦ខែហើយ

ដានី ៖ បាទ!សមាជិកក្រុមប្រឹក្សាឃុំបឹងប៉េងតាំងពីឆ្នាំណាម៉ោ?

ហ៊ិន ៖ ក្រុមប្រឹក្សាឃុំបឹងប៉េងបើតាមពិតខ្ញុំតាំងពីឆ្នាំ១៩៩៣ តាំងពីជំនាន់អ៊ុនតាក់ ។

ដានី ៖ រហូតដល់ឆ្នាំ២០០៨ហ្នឹង?

ហ៊ិន ៖ បាទៗ!រហូតដល់ឆ្នាំ២០០៨បានមកធ្វើក្រុមប្រឹក្សាស្រុកម្ដង ។

ដានី ៖ ចុះអ៊ំកាលពីអ៊ំនៅស្រុករៀនសូត្រដល់ណាដែរ?

ហ៊ិន ៖ ខ្ញុំរៀនទាបដែរ នៃថ្នាក់កុមារដ្ឋាន អើអទឹកដ្ឋានគ្រាន់តែចេះអានចេះសរសេរ ប៉ុន្តែខ្ញុំបួសបាន៩ឆ្នាំ អស់ថ្នាក់រៀនទៅបួសហើយរៀនបានបើប្រៀបធៀប យើងនៅលោកទេ តែបើប្រៀបធៀបនឹងអាណាចក្របានស្មើនឹងស្មៀវិកា ។

ដានី ៖ អ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់?

ហ៊ិន ៖ ខ្ញុំបងប្អូនបង្កើត១០នាក់?

ដានី ៖ អ៊ូ!ច្រើនដែរអ៊ំ?

ហ៊ិន ៖ បាទ!ខ្ញុំបងប្អូនច្រើនណាស់ ចុះយើងពីពីជំនាន់ហ្នឹង រហូតដល់មកខ្ញុំក៏ច្រើនដែរបានមកកូនរាល់ថ្ងៃច្រើន ។

ដានី ៖ ប៉ុន្មាននាក់ដែរកូន?

ហ៊ិន ៖ ៧នាក់

ដានី ៖ ៧នាក់ហ្នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហ៊ិន ៖ ស្រី៣ ប្រុស៤

ដានី ៖ គាត់ធំៗអស់ហើយ?

ហ៊ិន ៖ នៅសល់តូចៗ៣នាក់ទៀត ៤នាក់ទៀតមានគ្រួសារអស់ហើយ ។

ដានី ៖ ចុះអ៊ំបងប្អូន១០នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហ៊ិន ៖ ប្រុស៦ ស្រី៤ តែស្លាប់អស់ហើយនៅសល់តែប៉ុន្មានទេ៦-៧នាក់ នៅសល់៦នាក់ទេ ។

ដានី ៖ ចុះអ៊ំកូនទីប៉ុន្មាន?

ហ៊ិន ៖ ខ្ញុំកូនទី៧

ដានី ៖ ឪពុកម្ដាយអ៊ំគាត់ធ្វើអី កាលពីអ៊ំនៅតូចៗ?

ហ៊ិន ៖ គាត់កសិករធ្វើស្រែ ធ្វើចំការធម្មតា

ដានី ៖ គាត់ឈ្មោះអីដែរឪពុកអ៊ំ?

ហ៊ិន ៖ ឪពុកឈ្មោះ ហួន

ដានី ៖ ចុះម្ដាយ?

ហ៊ិន ៖ ម្ដាយឈ្មោះ សេង គាត់ស្លាប់អស់ហើយ ស្លាប់កាលជំនាន់អ៊ុនតាក់ ។

ដានី ៖ គាត់ទើបស្លាប់ដែរ?

ហ៊ិន ៖ បាទ!ខុសគ្នាតែ៤ឆ្នាំ បើចាំតែ៩៧បានជួបហើយ តែគាត់មិនចាំឯងសោះ ។

ដានី ៖ ចុះអ៊ំចេញពីផ្ទះដូចថាយើងចេញពីការតស៊ូតាំងពីឆ្នាំណា?

ហ៊ិន ៖ ចាំមើលខ្ញុំនិយាយពីប្រវត្តិបន្តិច មើលដល់ខ្ញុំឈប់រៀនទៅបួស ដល់បួសសឹកពីបួសខ្ញុំទៅរៀនវិញចូលរៀនវិញ តែដល់ទៅចូលរៀនអត់បានរៀនទេ ដល់គេយកទៅជួយជំនួយការងារគេ ហើយខំរៀនទាំងយប់ ជួលសាលាគេរៀនយប់ ដល់ហើយដល់ឆ្នាំ៦៨ចូល៦៩ ហើយដល់៧០រដ្ឋប្រហារគេវៃគេវៃលន់ ណុល ហើយខ្ញុំរត់ម៉ោរត់ម៉ោក៏ជួបអ្នកតស៊ូ អាហ្នឹងគេហៅថាចលនាតស៊ូចូលព្រៃម៉ាក់គីៗនោះណា ។

ដានី ៖ បាទ!កាលជំនាន់នោះសម្ដេច

ហ៊ិន ៖ បាទ!ដម៉ោជួបនឹងគេមានបានមកដល់ផ្ទះឯណា ម៉ោដល់ក៏ចូលនឹងគេនេះទៅ ចុះយើងបានជួបគេហើយ ។

ដានី ៖ ឆ្នាំណាហ្នឹង?

ហ៊ិន ៖ ឆ្នាំ៧០

ដានី ៖ ខែណាអ៊ំមានចាំទេ?

ហ៊ិន ៖ ដូចខែ មេសា ឆ្នាំ៧០ ខែគេទំលាក់សម្ដេច ។

ដានី ៖ ថ្ងៃគេទំលាក់សម្តេចថ្ងៃ១៨ មីនា?

ហ៊ិន ៖ អ៊ើៗថ្ងៃ១៨ មីនា ហ្នឹងហើយ ប្រហែលជាខែមេសា ព្រោះទំលាក់ហើយប្រហែលមួយខែទៀតបានខ្ញុំ កុំអីមិនគិតថាម៉ោដែរ ប៉ុនដឹវៃទៅរត់ម៉ោទាំងខោខ្លីទៅ អត់មានបានអីរលីងម៉ោដល់ជួបនឹងគេអ្នកខ្មែរតស៊ូពីនេះទៅ ខ្មែរអ្នករំដោះគេនោះណា ។

ដានី ៖ ពូមានចាំឈ្មោះពួកគាត់ទេអ្នកណាខ្លះ?

ហ៊ិន ៖ ពីណា?

ដានី ៖ អ្នកដែលខ្មែរតស៊ូ?

ហ៊ិន ៖ ខ្មែរតស៊ូបើតាមពិតស្លាប់អស់ហើយ ចាំតែស្លាប់អស់ហើយ

ដានី ៖ ខាងណាកាលហ្នឹងខាងអីគេ?

ហ៊ិន ៖ ខាងហ្នឹងគេហៅខាងអ្នកតស៊ូ អ្នករំដោះជាតិ រណសិរ្សរំដោះជាតិ ។

ដានី ៖ បាទ!អ៊ំទៅធ្វើអីគេកាលហ្នឹង?

ហ៊ិន ៖ ខ្ញុំមិនធ្វើអីផង គ្រាន់តែគេទៅគេឲ្យមានអ្នកដែលម៉ោជុំគ្នាទៅ ព្រោះខ្ញុំគេហៅថាចាស់ជាងនោះណា ថាចាស់ជាងគេចុះមាក្នុងចំណោមហ្នឹងណា ព្រោះកាលអ្នកតស៊ូកាលនោះសុទ្ធតែអ្នកនៅជនបទមិនចឹងអេស៎? ដូច្នេះគ្នាមិនសូវបានសិក្សារៀនសូត្រអីទេ ពេលលះបង់ចូលជួរទៅបំរើរណសិរ្សរំដោះជាតិហ្នឹងទៅ ក៏គេឲ្យបង្ហាត់បង្រៀនអក្សរលេខអញ្ចឹងទៅ ចាំពេលត្រូវការដូចគេត្រូវយកទៅធ្វើទ័ពរំដោះឲ្យទៅៗ ទៅធ្វើពេទ្យក៏ឲ្យទៅ ទៅធ្វើនេះក៏ឲ្យទៅ ដូច្នេះអ្នកដែលចូលទៅគឺចូលកន្លែងខ្ញុំនេះឯង ។

ដានី ៖ កាលហ្នឹងមន្ទីរគេ ឬគេហៅអីទៅកន្លែងមន្ទីរហ្នឹង?

ហ៊ិន ៖ គេហៅមន្ទីរ ។

ដានី ៖ មន្ទីរអីគេ?

ហ៊ិន ៖ មិនដឹងគេហៅមន្ទីរអីខ្ញុំមិនដឹងដែរ ។

ដានី ៖ កាលហ្នឹងអ៊ំនៅក្នុងមន្ទីរដូចថាមន្ទីរតំបន់ ឬក៏មន្ទីរស្រុក?

ហ៊ិន ៖ តំបន់នៅតំបន់កាលហ្នឹង ។

ដានី ៖ តំបន់អីគេកាលហ្នឹង?

ហ៊ិន ៖ តំបន់៤៣ ។

ដានី ៖ តំបន់៤៣ ពីព្រោះកាលហ្នឹងភូមិភាគ៣០៤?

ហ៊ិន ៖ បាទ! ភូមិភាគ៣០៤តំបន់៤៣ ៤១-៤២-៤៣ ហ្នឹងហើយត្រូវហើយតំបន់៤៣ ។

ដានី ៖ ចំការលើ?

ហ៊ិន ៖ កំពង់ចាមមាន៧តំបន់ ខេត្តកំពង់ចាមទាំងមូលមានតំបន់៤១-៤២ បានកំពង់ធំតំបន់៤៣ កាលនោះភូមិភាគឧត្តរ រួមទាំងសៀមរាបមួយផង ។

ដានី ៖ បាទ!សៀមរាប៣៥?

ហ៊ិន ៖ បាទ!

ដានី ៖ កាលហ្នឹងកុយ ធួន គាត់ប្រធានភូមិភាគ៣០៤?

ហ៊ិន ៖ អើស៎!ខ្ញុំមិនដែលស្គាល់គាត់ផង ដែលតែឮឈ្មោះតែមិនដែលឃើញមុខផង ។

ដានី ៖ ចុះនៅតំបន់៤៣ អ្នកណាគេប្រធាន?

ហ៊ិន ៖ មិនដឹង ខ្ញុំទៅនឹងមិនដឹងព្រោះខ្ញុំនៅម៉ារយៈពេលខ្លីដែរ នៅប្រហែលម៉ាខែ-២ខែ-៣ខែមិនដឹងកាលហ្នឹងបានជាគេដកខ្ញុំឲ្យមកនៅពាណិជ្ជកម្មភូមិភាគកណ្តាលតែខ្ញុំជាសមាជិកគេគេទេ ។

ដានី ៖ នៅកន្លែងណា?

ហ៊ិន ៖ ខ្ញុំចល័ចកន្លែងដូចគ្មានកន្លែងពិតប្រាកដផង ប៉ុនដូចខ្ញុំទៅដល់កំពង់ចាមដែរ ព្រោះអ្នកដឹកនាំនៅឯងសៀមរាប មានត្រីងៀត មានត្រីស្ងួតៗដូច្នេះខ្ញុំអ្នកយកសំភារៈមានដូចជា ត្រីងៀតខ្ញាញ់ដែលខាងយុវជនបាន ដូច្នេះខ្ញុំអ្នកដឹកនាំយកទៅអូររាំងឪអុះ បាទទៅដល់អូររាំងឪយើងដោះដូរជាមួយវៀតណាមកាលហ្នឹង ប៉ុនខ្ញុំធ្វើតែយប់ទេ ។

ដានី ៖ យើងជិះអីទៅកាលហ្នឹង?

ហ៊ិន ៖ ជិះកង់ ហើយដឹកសុទ្ធតែ១០០គីឡូអ៊ុះ ។

ដានី ៖ មានគ្នាច្រើនទេ?

ហ៊ិន ៖ បាទ!ច្រើនគ្នា ទៅម្តង៤០០កង់ ប៉ុនចែកគ្នាជាកងៗ អញ្ចឹងបានថាបើគិតពីពេលនោះមកដល់ឥឡូវ

ដានី ៖ ឆ្នាំណាអាំដែលដឹកត្រីងៀតត្រីអី?

ហ៊ិន ៖ ដែលដឹកត្រីងៀតឆ្នាំ១៩៧៣ កាលដែលអាមេរិចកាំងវាយកបេ ស្រុកយើងសង្គ្រាមគេហៅថាសង្គ្រាមអាកាស២០០យប់២០០ថ្ងៃ កាលនោះអត់ហានដើរថ្ងៃ ដើរតែយប់ទេ ។

ដានី ៖ អញ្ចឹងយើងដឹកត្រីងៀតដឹកត្រីអីមកដូរជាមួយអើអី?

ហ៊ិន ៖ យកដូរវៀតណាមហ្នឹងមានកាណាត់ មានថ្នាំពេទ្យ ពិសេសយកថ្នាំពេទ្យ ។

ដានី ៖ យកកាណាត់ និងថ្នាំពេទ្យ?

ហ៊ិន ៖ បាទ!អាហ្នឹងដែលយើងចង់បាន តែប្រសិនបើយើងអត់មាន ឧទាហរណ៍ថា កាលហ្នឹងនៅគិតលុយដែរ ចាយលុយដែរក៏គិតជាលុយទៅ ឧទាហរណ៍យើងយករបស់ទៅប៉ុនេះ របស់យើងគិតជាលុយប៉ុន្មាន ហើយរបស់គេគិតជាលុយម៉ោប៉ុន្មានដូរច្នេះថ្នាំពេទ្យហើយនឹងកាណាតវាអត់គ្រប់លុយយើងៗយករបស់អីដែលគ្រប់ដូចជាអំបិលអីម៉ោណាស់ ។

ដានី ៖ បាទ!ដល់ពេលនេះយើងដឹកយកមកដាក់កន្លែងណាវិញ?

ហ៊ិន ៖ យកម៉ោដាក់ហែរខ្ញុំយកម៉ោមើល៍ដាក់ទីស្នាក់ការមួយនៅឯសឹងជីនិតនៅកំពង់ថ្មនោះ ។

ដានី ៖ បាទៗ ។

ហ៊ិន ៖ ជួនកាលគេឲ្យមកដាក់នៅកន្លែងសាន់គរមួយកន្លែង សាន់គរនៅកំពង់ស្វាយយើងហ្នឹងស្គាល់សាន់គរទេ?

ដានី ៖ ស្គាល់ៗ?

ហ៊ិន ៖ បាទ!ហើយកាលណាយកមកដល់ម៉ោព្រំប្រទល់ស្រុកជុំ ភ្លេចអស់ហើយយូរពេក ។

ដានី ៖ យើងដាក់នៅមន្ទីរ?

ហ៊ិន ៖ បាទ!នេះតាមការចាត់ចែងថ្នាក់លើថាដាក់ឯណាៗអញ្ចឹងណា៎ ។

ដានី ៖ កាលហ្នឹងពាណិជ្ជកម្មភូមិភាគ?

ហ៊ិន ៖ បាទ!ពាណិជ្ជកម្មភូមិភាគ ។

ដានី ៖ គ្នាច្រើនដែរ?

ហ៊ិន ៖ ច្រើន គ្រាន់តែខ្ញុំទទួលបន្ទុក ជួនកាលបរទេសទៅម៉ងនៅជិតបរទេសទៅ ដូចថាយើងយកទៅត្រឹមចំការលើ មើលទៅកង់ពិបាកពេកដាក់រទេសទៅ ប៉ុនទាល់តែ៣យប់៣ថ្ងៃបានដល់ប៉ុនកង់វាយ៉ាប់ពេកទៅខាងហ្នឹងជីឡាច់ដូចនៅម្ហូរបាក់ក្រេសុទ្ធតែដីឡាច់ ដូចគេហៅដីអាមេ រិចៗចេញពីសន្ទុកទៅកើតគេធ្វើថ្នល់មួយទៅភ្លីង ។

ដានី ៖ អញ្ចឹងទៅពាណិជ្ជកម្មភូមិភាគអត់ដែលជួប កុយ ធួនទេ?

ហ៊ិន ៖ អត់ដែលទេ ។

ដានី ៖ ចុះក្នុងគណៈពាណិជ្ជកម្មភូមិភាគមាន៣នាក់?

ហ៊ិន ៖ អត់ដឹង!ខ្ញុំដូចមិនដឹង ប៉ុនកាលទៅខ្ញុំមិនហានសួរគេ ។

ដានី ៖ ប៉ុនអ៊ំជាសមាជិក?

ហ៊ិន ៖ អត់ទេ!ខ្ញុំជាបុគ្គលិកគេ សមាជិកគេបន្ទាប់ពីពលតូ ស្រេចតែគេប្រើទេខ្ញុំ

ដានី ៖ បាទ!អញ្ចឹងអ៊ំនៅហ្នឹងរហូតដល់ពេលណាទៅ?

ហ៊ុន ៖ នៅទល់តែ មើលថ៌ខ្ញុំនៅតិចទៅ គេដកឲ្យយកទៅធ្វើទ័ពមួន ធ្វើទ័ពឆ្នាំ៧៤ ៧៤កាលនោះគេប្រុងវៃរំដោះទីក្រុងភ្នំពេញហើយណាស់ ដឹទៅវៃកាលហ្នឹងខ្ញុំនៅកងតូច ។

ដានី ៖ កងពលណាទៅ?

ហ៊ុន ៖ កងពលភូមិភាគ ប៉ុនស្គាល់តែឈ្មោះទេ មេកងពលនេះឈ្មោះតាហុង ប៉ុនខ្ញុំនៅវរសេនាតូចនែ៎!ស្មឹទេភ្លេចបាត់ហើយ ។

ដានី ៖ ចុះកាលវៃចូលទីក្រុងភ្នំពេញក្រែងខាង?

ហ៊ុន ៖ ប៉ុនខ្ញុំនៅកំពង់ធំ នៅស្រុក

ដានី ៖ ទ័ពភាគហ្នឹងកាលហ្នឹងមានកងពលលេខ១-២-៣ មានកងពលរបស់តាអឿនអីកងពល៣១០?

ហ៊ុន ៖ បាទ!ខ្ញុំអត់បានសួរនាំអីទេ ប៉ុនគេថា១នៅកងភាគហើយ ចូលកងភាគហើយព្រោះគេដូរស់ខោអាវអាស់ ពេលចូលទៅបានមួយខែគេឲ្យស្លៀកខោអាវជ្រលក់មិនចឹង ។

ដានី ៖ បាទៗ!

ហ៊ុន ៖ ដល់ពេលបានមួយខែទៅបានគេថាចូលភាគហើយ ឥឡូវឡើងទៅវៃភ្នំពេញ ប៉ុនវៃកំពង់ធំសិនមិនចឹងអាស់ ដល់ហើយទៅវៃអារលួស ដល់វៃអាលោកម៉ាកងតូចគិតទៅនៅសល់តែគ្នា៦នាក់ ។

ដានី ៖ ម៉ាកងតូចប៉ុន្មាននាក់?

ហ៊ុន ៖ ៣២នាក់ ពីដើមខ្ញុំថាទៅដែរ តែមានអនុរងអាស់ អនុរងកងតូចហ្នឹងគេថាបងមិនបាច់ទៅទេនៅចាំកន្លែង ខ្ញុំនៅចាំកន្លែងនៅជាយស្បៃនៅជិតភ្នំសន្ទុកនេះ ហើយកងគេឡើងទៅវៃរលួស វៃខាងត្បូងទីរួមខេត្ត ។

ដានី ៖ វៃយកកំពង់ធំហ្នឹង?

ហ៊ុន ៖ បាទ!អេស់អាហ្នឹងដូចថាបន្ទាយវា ដែលយើងហៅថាប្រមោយវាឡើងទៅវៃ ដល់ឡើងទៅ វៃកងខ្ញុំនេះឡើងចំអាបូស ដល់ពេលរំដោះ៧៥ហើយ ខ្ញុំចូលទៅឃើញនៅហ្នឹងពេទ្យ នេះខ្ញុំក៏បញ្ជូនឲ្យមកសៀមរាប គ្រូខ្មែរឲ្យគេមើលនៅសៀមរាបតែមិនដឹងទៅណាទៅ ។

ដានី ៖ បាទ!ចុះចូលកងទ័ពរហូតដល់បែក៧៥?

ហ៊ុន ៖ អត់ទេ!ខ្ញុំដល់វៃបួសរួចហើយបានជួបនឹង យើងពីដើមគេហៅអភិបាលស្រុកហើយណាស់ជួបនឹងគណស្រុក១ធ្លាប់កាលហ្នឹងនៅអាកន្លែងនេះ ធ្លាប់ទំនាក់ទំនងជាមួយគាត់ណាស់ គាត់មកលេងមកអីស្គាល់គ្នាបើតាមគាត់ស្គាល់គ្នាតាំងពីដឹបូងម៉ោ ដល់ពេលអាវៃនោះឯគេរបួស

ខ្លាំង  ដីរបួសខ្លាំងត្រូវការអ្នកសែងអ្នករបួសយកមកដាក់ពេទ្យ  ដីម៉ោក៏ជួបនឹងគាត់  ដីជួបគាត់ៗថាហ៊ីម៉ោពីណាមិត្តឯង  (គេហៅខ្ញុំមិត្ត)ខ្ញុំថាម៉ោណាខ្ញុំសែងអ្នករបួសមកដាក់ពេទ្យ គាត់ថាហ៊ីមិត្តឯងនៅទ័ពរាល់ថ្ងៃ  បាទ!ខ្ញុំម៉ោ៣-៤ខែហើយបង  ដីហើយគាត់ចុះពីលើសេះ គាត់ជិះសេះ ៗ

ដានី : គាត់ជិះសេះ?

ហ៊ុន : ជិះសេះចុះគណប្រតិភូ  ចុះនៅក្នុងព្រៃ  ដល់ហើយគាត់ទាញក្រដាសពីកាតាបគាត់ម៉ោ  គាត់សរសេរៗគាត់បត់ឲ្យក៏មិនបានគិតថាមើល  មិត្តយកអានេះទៅឲ្យមិត្តជូផង ៗ

ដានី : មិត្តជូហ្នឹងគាត់ធ្វើអីគេ?

ហ៊ុន : មិត្តជូគាត់នៅក្នុងពាណិជ្ជកម្មជាមួយគ្នាស្គាល់គ្នានោះណា  ឥឡូវមិត្តឯងយកសំបុត្រនេះទៅឲ្យមិត្តជូផង  ខ្ញុំក៏យកអ្នកជំងឺទៅដាក់ពេទ្យរួចរាល់អស់ហើយ  ក៏យកសំបុត្រទៅឲ្យមិត្តជូ  ហ្នឹងឯង ដីទៅឲ្យមិត្តជូលាមើល  គេថាអ៊ីបានគ្នាទៀតហើយឯងកំពុងខ្វះគ្នាផង  នែ៎!គាត់ឲ្យនៅជាមួយមិត្តជូ  ទៅធ្វើទ័ពអាស់៎  ខ្ញុំនៅជាមួយជូទៅ ខ្ញុំនៅពាណិជ្ជកម្មទៅ ៗ

ដានី : ពាណិជ្ជកម្មអីគេហ្នឹង?

ហ៊ុន : ពាណិជ្ជកម្មស្រុក

ដានី : ស្រុកអីគេហ្នឹង?

ហ៊ុន : ស្រុកកំពង់ស្វាយ

ដានី : ចុះគាត់ហ្នឹង  គាត់គណស្រុកកំពង់ស្វាយ?

ហ៊ុន : គណស្រុកកំពង់ស្វាយ  ពីមុនកាលដែលស្គាល់គ្នាគាត់នៅគណស្រុកស្ទោង  ចាំមើលចេស់៎ កាលដែលស្គាល់គ្នា  ខ្ញុំកាលដែលនៅរៀនខ្ញុំមានពួកម៉ាកខ្ញុំមួយនៅរៀនអាស់៎!

ដានី : បាទ!

ហ៊ុន : ឈ្មោះអាប្រុញ  ដល់ហើយពេលយើងរដ្ឋប្រហារនេះទៅ  អាប្រុញនេះគេធ្វើរងគាត់នេះទៅរងឈ្មោះ  សុនហ្នឹង ៗ

ដានី : ឈ្មោះអីឈ្មោះសុន?

ហ៊ុន : បង  សុន  ប៉ុនមិនដឹងស្រុកស្រែកំណើតកើតជានៅណាទេ  យើងមិនដែលហានសួរគាត់  ប៉ុនខ្ញុំមានពួកម៉ាកខ្ញុំឈ្មោះ  អាប្រុញហ្នឹងវាធ្វើរងនៅហ្នឹង  បានគាត់ស្គាល់គាត់ហ្នឹង  ស្គាល់ក៏មិនដែលនិយាយគ្នាដែល  គ្រាន់តែជួបគ្នាសួរគ្នាថាទៅណាមកណាតែប៉ុណ្ណឹង  បាននៅជាមួយគ្នាទល់ដល់យើងរំដោះ៧៥  រំដោះ៧៥ហើយទៅខ្ញុំក៏នៅពាណិជ  កាលនោះគេហៅពាណិជ

ប៉ុនដល់ពេលនោះចប់ទៅគេកាលៃគេផ្លាស់ប្តូរពីពាណិជទៅខាងភ័ស្តុភាស្រុក ហើយភ័ស្តុភាស្រុកគេកាលនោះអ្នកដឹកនាំអង្គការនោះរៀបចំថាឲ្យចាយលុយចាយអីកាលហ្នឹង ។

ដានី ៖ បាទ!

ហ៊ុន ៖ ហើយខ្ញុំបានឃើញក្រដាសប្រាក់នឹងក្រដាស៥០ គេបោះប្រាក់ម៉ៅ ដល់ហើយបានគាត់ថាម៉េចមិនចាយលុយ ។

ដានី ៖ គាណា?

ហ៊ុន ៖ គាពល ពតមិនដឹង ខ្ញុំមិនដឹងដែរ ហើយគេក៏រំសាយភស្តុភា រំសាយភ័ស្តុភាម៉ៅក៏មកនៅកងចល័ត ។

ដានី ៖ កាលហ្នឹងអ៊ំដឹងថានៅ ហួរ យួន គាត់ចង់ឲ្យចាយលុយ?

ហ៊ុន ៖ ចង់ឲ្យចាយលុយ ។

ដានី ៖ ម៉េចបានអ៊ំដឹង?

ហ៊ុន ៖ ដឹងតាមរយៈគ្នាឯងគេនិយាយ មិនបានប្រជុំទេ ព្រោះខ្ញុំបើតាមពិតគេមិនសង់ស្គាល់ផងមិនមានតួនាទីអីផង គ្រាន់តែគេប្រើឲ្យទៅខាងណាយើងទៅខាងនោះ ហើយយើងកាលហ្នឹងយើងដឹងស្រាប់ហើយ យើងមិនមានសេរីភាពក្នុងការចង់ដឹងចង់ឮអីទេ ឲ្យតែគេធ្វើអីយើងធ្វើនោះ នេះបានយើងរស់ យើងអត់ដឹងឮថាម៉េចៗទេ គេឲ្យហូបម៉េចស៊ីម៉េច បេះតែធ្វើ ទៅធ្វើការធ្វើទៅ ទៅណាទៅៗ ប៉ុនបើគេថាឲ្យទៅណាយើងទាល់តែទៅដល់នោះ អញ្ចឹងបានរួចខ្លួនមិនចឹង!

ដានី ៖ បាទ!

ហ៊ុន ៖ ខ្ញុំឃើញ ខ្ញុំបានឃើញក្រដាស៥០ ប្រឡាំៗនឹងក្រដាសថៃដែរ ។

ដានី ៖ ចុះអ៊ីពេលហ្នឹងគេអត់ចែកលុយឲ្យយើងគេរំសាយអង្គភាពភស្តុភា?

ហ៊ុន ៖ បាទ!ហ្នឹងហើយ ខ្ញុំនេះគេឲ្យទៅនៅកងចល័ត ។

ដានី ៖ កងចល័តអីគេទៅកាលហ្នឹង?

ហ៊ុន ៖ កងចល័តនោះគេ កងចល័តធ្វើស្រែ ប៉ុនគេឲ្យទៅគ្រប់គ្រងដែរ ឲ្យទៅគ្រប់គ្រងយុវជនយុវនារីនៅពេលដែលរំដោះហើយ គេរៀបចំកងចល័តខ្ញុំទៅគ្រប់គ្រងកងចល័ត ។

ដានី ៖ របស់ស្រុកកំពង់ស្វាយហ្នឹង?

ហ៊ុន ៖ របស់តំបន់ ប៉ុនខ្ញុំតួនាទីខ្ញុំកាលនោះជាប្រធានកងរយ មានគ្នា១០០នាក់ជាងដែរ មាននារី៥០-៦០អញ្ចឹង មានយុវជន៥០-៦០ដែរទៅណា ។

ដានី ៈ បាទ!ចុះពួកគាត់ហ្នឹង ពួកកូនអ្នកស្រុកអ្នកភូមិហ្នឹងឬក៏យ៉ាងម៉េចនៅកងចល័ត?

ហ៊ិន ៈ នៅកងចល័តហ្នឹងកាលហ្នឹងលាយគ្នា កាលខ្ញុំទៅគ្រប់គ្រងហ្នឹងណា៎ មានកូនអ្នកស្រុកអ្នកភូមិក្នុងខេត្តហ្នឹងផង ហើយមានអ្នក១៧មេសាដែលគេជម្លៀសពីទីក្រុងភ្នំពេញម៉ោនោះ ។

ដានី ៈ អញ្ចឹងកងចល័តតំបន់មានគ្នាច្រើន?

ហ៊ិន ៈ ច្រើនម៉ាកងពល ចាំមើលខ្ញុំនិយាយប្រវត្តិ ខ្ញុំមកកាលនោះខ្ញុំភ័យខ្លាំងណាស់កាលនោះខ្ញុំគិតថាខ្ញុំមិនរស់ដែរ ក្នុងពេលណានោះទៅជួបនឹងដែលខ្ញុំនិយាយថាឈ្មោះជួ ជួគេធ្វើកងពល ។

ដានី ៈ បាទ!

ហ៊ិន ៈ តែឥឡូវពាក្យដូចមិនពិត ប៉ុនគេចាប់ កាលហ្នឹងថ្នាក់តំបន់ឈ្មោះតាចន ។

ដានី ៈ ស្គាល់គាត់ដែរ?

ហ៊ិន ៈ អត់ទេខ្ញុំអត់ស្គាល់ទេ!

ដានី ៈ ធ្លាប់ឃើញគាត់ដែរ?

ហ៊ិន ៈ មិនដែលធ្លាប់ឃើញផង ខ្ញុំធ្លាប់ឃើញតែត្រឹមថ្នាក់ស្រុកដូច តាអឿន តាគឿន

ដានី ៈ តាអឿនហ្នឹងប្អូនថ្លៃតាពកអី?

ហ៊ិន ៈ អេស៎!តាចនគណៈតំបន់ទេ ប្អូនថ្លៃតា កែវ ពក ទៅនៅក្រវាញ ដ៏ហើយគេចាប់

ដានី ៈ ចាប់ពីណាគេ?

ហ៊ិន ៈ ចាប់តាជួ តាជួហ្នឹងធ្វើកងពល ហើយខ្ញុំបើគិតកងវរយទេ ហើយវរៈសេនាធំក៏ចាប់ដែរ វរៈសេនាធំហ្នឹងឈ្មោះ តាកោ ។

ដានី ៈ ឈ្មោះតាអី?

ហ៊ិន ៈ តាកោ ក៏គេចាប់ដែរ តែខ្ញុំរត់ចេញបាត់ទៅហើយ ដល់ពេលគេចាប់ហើយរត់ ។

ដានី ៈ រត់ទៅណា?

ហ៊ិន ៈ ចាំមើលខ្ញុំនិយាយពីប្រវត្តិរត់ ដល់គេចាប់តាជួ ចុះចាប់តែតាម្នាក់ ខ្ញុំនឹកឃើញថាច្បាស់តែតាជួ ឆ្លើយដាក់អញហើយ គេហៅទៅប្រជុំថា តាចន ហៅទៅប្រជុំនៅកន្លែងតាហុកកងពលដែរ ដ៏អារម្មណ៍វាគិតច្រើនពេកវាភ័យពេកជិះ១កង់ស្រាប់តែហួស ហួសទៅដល់ព្រែកស្បូវនៅ ក្រោមទៅដល់ទៀមក្រែង ដ៏ខ្ជិលទៅប្រហួសបណ្ដោយទៅរត់ទៅបណ្ដោយ រត់ម៉ោជួបជាមួយបងប្អូននៅភូមិកំណើត ។

ដានី ៈ បាទ!

ហ៊ិន ៈ ពេលយប់ពុស្សូវតែរទេះផែក១រទេះណាខ្ញុំចាំមើល ដ៏យូរបន្តិតខ្ញុំបោះកង់ចោលហត់ពេក

ដានី ៖ ឆ្នាំណា?

ហ៊ិន ៖ ឆ្នាំ៧៦ ចូល៧៦ហើយ

ដានី ៖ ចុះការហ្នឹងថាដូ កងពលចល័តហ្នឹងគេចាប់?

ហ៊ិន ៖ គេចាប់ ។

ដានី ៖ ម៉េចបានអ៊ំដឹងថាគេចាប់?

ហ៊ិន ៖ ចុះមានគេមកប្រាប់ អានិរសានៅជាមួយហ្នឹងមិនធ្លាប់ស្គាល់ខ្ញុំ ។

ដានី ៖ ដល់ពេលគេហៅប្រធានហៅអ៊ំមកប្រជុំអញ្ចឹងអ៊ំភ័យ?

ហ៊ិន ៖ ភ័យ ថាតែគេហៅមកប្រជុំទៀតចាប់ខ្ញុំទៀតហើយ ជិះកងមកប្រជុំនៅតាមកងចល័តមិន ជិះតាមអាប្រព័ន្ធភ្លឺស្រែគេ ជិះៗម៉ោស្រាប់តែធ្លាយទៅណានោះវិញ ជិះៗទៅមិនម៉ោ កន្លែងតាហុកគាត់នៅទីរួមខេត្ត ។

ដានី ៖ តាហុកគាត់ធ្វើអី?

ហ៊ិន ៖ កងពល

ដានី ៖ កងពលតំបន់?

ហ៊ិន ៖ កងពលភាគ ប៉ុនគេប្រាប់កន្លែងបណ្ណាល័យពីសង្គម កន្លែងដែលគេដាក់លក់សៀវភៅ ដាក់តាំងសៀវភៅកន្លែងគាត់នៅហ្នឹងឯង ដល់ពេលនេះចេះរត់ម៉ោៗកុំអីក៏ត្រូវស្លាប់ដែរ ប៉ុនបានប្អូនជីដូនមួយគេធ្វើសន្តិសុខតំបន់ អានោះម៉ោជាមួយខ្ញុំដែរ រត់ម៉ោ៧៩ម៉ោជាមួយ ប៉ុនដឹមៅបែកគ្នាវាទៅអន្លង់វែងទៅក៏ជាន់មីនស្លាប់បាត់ទៅ ២នាក់ ។

ដានី ៖ ២នាក់ហ្នឹងប្អូនជីដូនមួយអ៊ំដែរ?

ហ៊ិន ៖ បងជីដូនមួយ

ដានី ៖ គាត់ធ្វើ?

ហ៊ិន ៖ ធ្វើសន្តិសុខតំបន់ ។

ដានី ៖ តំបន់ណា

ហ៊ិន ៖ តំបន់កំពង់ធំ តំបន់៤៣ ដល់ហើយខ្ញុំរត់ម៉ោ ខ្ញុំរត់ម៉ោមកដល់ផ្ទះៗក៏ឪនោះបញ្ជូនខ្ញុំឲ្យទៅនៅជាមួយអ៊ំ អ៊ំគាត់នៅចាំចំការតាឡូងឆ្ងាយពីភូមិចេះនៅទៅបានអាប្អូនជីដូនមួយនេះគេដើររៀនឲ្យទៅ បានគេចេះបំរៀន ប៉ុនគេចេះប្រើដូចថាខ្ញុំនៅពីមុនម៉ោខ្ញុំមានឥទ្ធិពលណាស់ អ្នកដែលធ្លាប់នៅជាមួយខ្ញុំគេខ្លះបានធ្វើពេទ្យតំបន់ទៅ ខ្លះបានធ្វើប្រធានសហករណ៍ទៅ ខ្លះបានធ្វើច្រើន ដូច្នេះគេចេះតែបំបរបង់ខ្ញុំគេចេះតែបំរៀន បំរៀនរហូតដល់ខ្ញុំបំរៀនទៅគេ

ឲ្យខ្ញុំទៅធ្វើនេសាទ កាល៧៩ដែលខ្ញុំរត់ហ្នឹងគេឲ្យទៅធ្វើនេសាទ ម៉ោនៅគ្រប់គ្រងនេសាទតំបន់ទៀតកាលហ្នឹង ។

ដានី ៖ នេសាទតំបន់នៅណាទៅ?

ហ៊ិន ៖ នៅឯតំបន់៤៣នេះ ចាប់ពីស៊ឹងសែនម៉ោខ្ញុំគ្រប់គ្រងទាំងអស់ អាពួកពីសហករណ៍ទៅមានខេត្តព្រះវិហារផង ខេត្តកំពង់ ស្រុកកំពង់ស្វាយ ស្រុកសណ្ដាន់ អេស៉ដូច៣ស្រុកស្រុកសន្ទុកផង អត់តែស្រុកស្ទោងមួយទេ ព្រោះស្រុកស្ទោងគេប្រកបនេសាទតាមដងស៊ឹងស្ទោង ខ្ញុំភ័យនឹង កែវ ពក ទៅម្ដងទៀត ព្រោះអ្នកដែលឲ្យខ្ញុំទៅថាបងឯងមិនបាច់ឡើងទេណា៎ មិនបាច់ឡើងទេធ្វើតែរបាយការណ៍ឲ្យគេទៅ គេហៅម៉ោបាន៦ខែទៅនៅហ្នឹងប៉ុនខ្ញុំដឹងខ្លួនថាខ្ញុំវាមានបាត់ ទៅដល់ខ្ញុំអត់តែងទូយាមទេ កាលមុនគេហៅកម្មាភិបាល ខ្ញុំធម្មតាស្លៀកខោអាវ ខោអាវហ្នឹងខ្ញុំមិនដែលស្លៀកទេអា ខោអាវកម្មាភិបាលអត់ដែលស្លៀកទេអាខោអាវខ្មៅ អាអាវខ្មៅ ខោខ្មៅ មានខោអាវពណ៌អាច់សេះ ខ្ញុំអត់ដែលទេដាក់វាតែក្នុងតេដេ ខ្ញុំស្លៀកតែខោអាវគេលក់អាគេបោះឈើ ទៅក៏ទៅធ្វើត្រីធ្វើអីជាមួយគេទៅ ទៅដល់ប្រាប់ថាឥឡូវស្រុកកំពង់ស្វាយចាត់ឲ្យមកយកត្រី ប៉ុនគ្រប់គ្រងពួកសហករណ៍ដែលទៅ ដល់ពេលអ្នកនេសាទមានផ្នែកគេផ្សេង ដល់ទៅចេះតែប្រាប់ឲ្យធ្វើត្រីប៉ុនខ្ញុំទៅលាក់ខ្លួននៅខេត្តព្រះវិហារ ព្រោះខេត្តព្រះវិហារមានឈ្មោះ អឹម ៗ គាត់ជនជាតិយើងនៅឯព្រះវិហារនៅស្រុករវៀង ខ្ញុំធ្លាប់ស្គាល់គាត់ពីមុនម៉ោខ្ញុំទៅលាក់ខ្លួននៅកន្លែងហ្នឹងដូចថាប្រាប់គេឲ្យធ្វើត្រី ព្រោះខ្ញុំមានបច្ចេកទេសជំនាញខាងធ្វើត្រីឲ្យធ្វើម៉េចៗប្រាប់ទៅខាងខ្ញុំចេះធ្វើត្រីឆ្អើរ ត្រីងៀត ហើយដល់ខាងព្រះវិហារមិនសូវចេះធ្វើខ្ញុំបានលេះនេះទៅ ។

ដានី ៖ ចុះអ៊ំម៉េចទៅអ៊ំនិយាយថាជួប កែវ ពក?

ហ៊ិន ៖ តា ពក គាត់ម៉ោតែមិនដឹងគាត់ម៉ោមានការអី ខ្ញុំភ័យម៉ាសារទៀត ស្មានតែគេមកចាប់ខ្ញុំភ័យអើយភ័យ ប៉ុនខ្ញុំអាងខាងនៅព្រះវិហារគាត់ចូលដែរ គាត់ម៉ោគាត់ដើរសួរនៅតាមកន្លែងនីមួយៗធ្វើបានប៉ុន្មានកម្មាភិបាល១ខែ ព្រោះខ្ញុំគេឲ្យអ្នកគ្រប់គ្រងអ្នកធ្វើត្រីផង គ្រប់គ្រងអ្នកធ្វើស្រែបណ្ដោញទឹកទន្លេផងវា២ដាន់អញ្ចឹងមិនទៅវានឹកឃើញ ។ ហើយបើថាយើងត្រូវធ្វើរបាយការណ៍ យើងទៅជួបទៅធ្វើបានប៉ុន្មានហត្ថៗអស់សំណាបប៉ុន្មានសរសេរម៉ោឲ្យគេទៅ ។ ហើយដល់ពេលបិទនេសាទខែ៦ ដ៏បិទនេសាទគេមាននិរសាគេម៉ោហៅៗដល់ហើយគេឲ្យឡើងម៉ោ គេថាពេលសំបុត្រទៅដល់ពេលណាសូមបងឡើងម៉ោពេលនោះហើយសំបុត្រដល់ថ្ងៃទៀត ប៉ុនទៅដល់ទៅដល់ខ្ញុំឡើងមកទៀត ទៅដល់មាននិរសាគេទៀត

ទៅដល់ខ្ញុំឡើងទៅ ឡើងម៉ោគេរៀបចំរួចស្រេចរៀបចំឥវ៉ាន់ហើយស្រេចមានអីៗ ឥឡូវគាហ្នឹងឆាប់បាត់ហើយ គាដែលគាត់រៀបចំ

ដានី : គាត់ឈ្មោះអីគេ?

ហ៊ុន : គេចាប់បាត់ ឈ្មោះ វ៉េន ។

ដានី : គាត់ធ្វើអីគេ?

ហ៊ុន : ប្រធានសហករណ៍ ប្រធានឃុំ

ដានី : នៅណាឃុំនៅណា?

ហ៊ុន : នៅនីពេជ្រ ប៉ុនស្រុកកំណើតគាត់នៅត្រែង ប៉ុនគាតទៅធ្វើប្រធានសហករណ៍នៅហ្នឹងទៅ នៅរៀបចំទៅ គេឲ្យទៅទុ៎ះព្រាំប្រទល់ព្រះវិហារ និយាយរួមទឹកដីព្រះវិហារមិនមែនទឹកដីកំពង់ធំទេ កាលនោះមានកម្លាំង៤០០ ធ្វើចំរុះ២០០ ធ្វើដ័រ២០០ ។ ធ្វើចំរុះ២០០ហ្នឹង ធ្វើចំរុះផង បោចវ័រផង ហើយចាក់យកទឹកផង ដល់ហើយទៅរៀបចំនោះទៅទាំងយប់គេ អត់ឲ្យម៉ោ ទៅនៅហើយគេប្រាប់ទៀតថាមិនបាច់ឡើងម៉ោទេ ខ្ញុំឆ្ងាតកាលនោះអាវ៉ាត់យួ គេបែកឲ្យអាវ៉ាត់យួចិន នោះរបបកម្មាភិបាលគេឲ្យខ្ញុំអត់ចោលទេអាហ្នឹងកាន់យកជាប់ចុះស្តាប់ពត៌មាន កុំតែនៅក្នុងព្រៃនេះទៅ កម្លាំង៤០០នៅឆ្ងាយប្រហែល២០០ម៉ែត្រ កម្លាំងធំគេនោះណា ហើយខ្ញុំមាននិសារ២នាក់ខ្ញុំទៅនៅឆ្ងាយពីគេ ហើយអានិសារហ្នឹងនឹក ពេលមានការអីៗព្រឹកឡើងវាម៉ោ ពេលមានគេទាក់ទងវាអ្នកនាំម៉ោ ប៉ុនខ្ញុំឆ្ងាតត្រង់ថាអាវ៉ាត់យួចិននេះនៅក្នុងព្រៃលែងពូម៉ង ប៉ុនខ្ញុំធ្វើអង់តែនដែកគោល យកម៉ៅវ័របោចបានចោះដែកគោលដាក់តឯងឲ្យផុតព្រៃ ហើយស្តាប់ៗតាមដានសភាពការណ៍ទៅបានខែ៨ ៧៨ គណៈ៨៧០ឋានះមជ្ឈិមវា ។

ដានី : បាទ!

ហ៊ុន : ចេញសេចក្តីប្រកាសលើកលែងទោសនិន្នាការនយោបាយទាំងអស់ ។

ដានី : កាលហ្នឹងអ៊ឹស្តាប់វិទ្យុត្រ?

ហ៊ុន : បាទ!ត្រ

ដានី : ត្រថា នៅខែ៨ ៧៨?

ហ៊ុន : បាទ!នៅខែ៨ ៧៨ហ្នឹងគណៈ៨៧០ចេញសេចក្តីប្រកាសលើកលែងទោស ។

ដានី : ពីណាគេអ្នកគណៈ៨៧០?

ហ៊ុន : មិនដឹងដែល ដូចអ៊ំ ខៀវ សំផន គណៈ៨៧០ចេញលើកលែងទោស ដ៏ចេញបាន

ប្រហែល៣ថ្ងៃ ខាងសន្តិសុខគេមកប្រាប់ថាបង ព្រោះយើងមេគេណា ប្រាប់ថាបងត្រឡប់ទៅវិញព្រោះសភាពការណ៍អត់ស្រួលទេ ដល់ពេលយប់ខ្ញុំចាប់ផ្តើមស្តាប់អាមេរិច ស្តាប់វៀតណាមផង ច្របូកច្របល់មែនទែន ប្រាប់ឲ្យម៉ោក៏ម៉ោ ម៉ោដល់នៅតែភ័យទេ មន្ទីរមួយនៅមិនថាយ៉ាំងម៉េចទេ មន្ទីរហ្នឹងមានកំពូលធំ ហើយគេចាប់មន្ទីរយកទៅបាត់ដល់ហើយពីមន្ទីរនេះទៅនៅមន្ទីរនោះ ហ៊ីគេចាប់បាត់ហើយ ភ័យទៀត មានឈ្មោះតាអ៊ីៗកាលនោះតាអ៊ីទៅធ្វើគណៈស្រុកកំពង់ស្វាយ កាលឆ្នាំ៧៨ គាត់ហៅប្រជុំ ។

ដានី ៖ តាអ៊ីហ្នឹងអ្នកស្រុកមកពីណាម៉ោ?

ហ៊ុន ៖ មិនដឹងដែរ ខ្ញុំមិនហានសួរទេ ។

ដានី ៖ ប៉ុនមានអ្នកនៅក្នុងស្រុកហ្នឹងទេ?

ហ៊ុន ៖ មែនទេ! នៅក្នុងខេត្តទេបែបពីកំពង់ចាម គាត់និយាយស្រដៀងៗហ្នឹង និយាយត្រីសៗប៉ុនមាឌធំ មកដល់គេឲ្យធ្វើស្មៀនៗសហករណ៍ ព្រោះឯងអ្នកចេះសរសេរ គេឲ្យម៉ោប្រជុំអានោះបានភ័យមែនទែនអាភ័យដល់ថ្នាក់ចេញនោម ដល់ទៅស្មៀនធំទាំងអស់ ស្មៀនសហករណ៍ឃុំទាំងអស់ទៅទាំងអស់គ្នាទៅជួបជុំគ្នា ទៅដល់ចុះគេប្រជុំចប់ហើយគេមិនជំរាបលាទាំងអស់គ្នា ជំរាបលាប្រធានមន្ទីរស្រុកគេ ដល់ហើយស្រាប់តែឈ្មោះអាភឿនៗនេះគេថាបងអត់ទាន់ឲ្យទៅទេ អឹគាត់ចង់ជួប អ៊ូនោះបានភ័យមែនទែនម៉ង ភ័យឡើងលែងដឹងលិចកើត ឡើងវង្វេងម៉ង ដល់ម៉ោកមិនដឹងធ្វើម៉េច នៅកន្លែងមិត្តភឿនវាមានកាស្ប មិនដែលអ្នកណាមានកាស្បទេយើងតាមសហករណ៍ឃុំមិនដែលមានទេ ហើយនឹងអគ្គកាលីលេខមិនដែលមានទេ ហើយខ្ញុំកាលនៅរៀនខ្ញុំធ្លាប់វៃអាអគ្គកាលីលេខនោះណ៎!

ដានី ៖ បាទ!

ហ៊ុន ៖ ដល់ហើយមានអគ្គកាលីលេខហ្នឹង ទៅចុចកាស្បអាភឿនគេសួរថាអាណាបូក ខ្ញុំថាចុះមិនឃើញសញ្ញាបូកអេស៎ ឃើញ បូក គុណ ចែក ស្អីៗរាសសីនការឯងសួរអញ ស្អីការាសីនការ ខ្ញុំថាអាភាគរយ ប្រហែលជាម៉ោង១០យប់បានតាអ៊ីនោះម៉ោ តាអ៊ីគណៈស្រុកគាត់ម៉ោៗប្រជុំមួយធំ ខ្ញុំនៅជាន់ខាងលើ ផ្ទះគេ២ជាន់ខ្ញុំនៅជាន់លើ

ដានី ៖ បាទ!

ហ៊ុន ៖ ដឹម៉ាសន្ទុកគេប្រាប់ថានោះអឹម៉ោហើយ អ៊ូភ័យឡើងចេញនោមដាក់ខោ ម៉ោដល់មានកៅអីមួយគាតលអង្គុយនៅដូចការិយាល័យអញ្ចឹង ខ្ញុំទៅដល់ទៅដល់បត់ជើង លើកដៃជំរាបសួរ គាត់គាត់ចាប់លើកដៃឡើងគាត់ថាអង្គុយៗយកកៅអីមួយអង្គុយ បានខ្ញុំបាត់ភ័យ ទាល់

ដាក់អង្គុយទល់មុខគ្នាបានគាត់សួរសភាពការណ៍សព្វបែបយ៉ាង ហើយរាយការណ៍ពីប្រវត្តិខ្ញុំចេះៗទៅណា៎ ថាខ្ញុំមិនដែលបានចូលអង្គការ មិនដែលបានចូលបដិវត្តន៍អីគេទេ ព្រោះខ្ញុំជាជនបំរើគេ ម្យ៉ាងវាអត់ស្របនឹងគោលនយោបាយមាគ៌ារបស់បក្ស គេថាឯងបើគិតទៅជាបញ្ញាវ័ន្តបញ្ញាជនអីនោះណា៎ ចេះសរសេរចេះដឹងជាងគេ គេឲ្យចូលបក្សទាល់តែកសិករក្រ យើងចេះតែប្រាប់គាត់ហូរហែរទៅណា៎!

ដានី ៖ បាទ!

ហ៊ិន ៖ ហើយបានគាត់និយាយពីសភាពការណ៍បច្ចុប្បន្នក្នុងផ្ទៃក្នុង មានអីទេបងប្អូនមានដីកនាំៗ វាមានសហករណ៍តាមសហករណ៍ តាមមូលដ្ឋានអីមិនដែលបញ្ហាអីនៅក្នុងឃុំទាំងពីរនេះមិនដែលមានបញ្ហាអីទេ ម៉ោធ្វើជាប់ខ្ញុំហៅម៉ោប្រជុំព្រោះខ្ញុំនៅជាមេនោះឯងដូចជាមេឃុំអាស៎

ដានី ៖ បាទ!

ហ៊ិន ៖ ឲ្យហៅទាំងពីរឃុំមកប្រជុំទៅ មិនដែលមានបញ្ហាអីទេ អ៊ើ!ឥឡូវអត់អីទេ ឯងអត់អីទេ អរគុណអ៊ំ អូស៎បងខ្ញុំហៅគាត់បង អរគុណបង ដល់ហើយយូរគាត់សួរនាំច្រើន ដល់ហើយបានគាត់ថាសម្រាក់ហ្នឹងហើយ ចាំព្រឹកចាំទៅ ដល់ព្រឹកឡើងខ្ញុំម៉ោ ម៉ោបានប្រហែលជា៣ថ្ងៃបានគាត់ម៉ោ ម៉ោដល់ខ្ញុំ អ៊ើ!យើងចេះរៀបចំខ្ញុំជូនគាត់ឡើងទៅមន្ទីរខ្ញុំនោះឯងវាមានជាន់លើ ។

ដានី ៖ បាទ!

ហ៊ិន ៖ ផ្ទះប្រជាជនធម្មតាមិនមានជណ្តើរឡើង ពេលគាត់ទៅដល់ក៏ចុះមៅអញ្ជើញគាត់ឡើងទៅលើទៅខ្ញុំក៏ចុះម៉ោ រុញម៉ូតូគាត់រក្សាឲ្យមានរបៀបរៀបរយ ហើយខ្ញុំអង្គុយនៅក្រោមបានឈ្មោះបងនោះ ប៉ុនឥឡូវគាត់ស្លាប់ហើយ ស្លាប់ឈឺគ្រុនចាញ់ពេលម៉ោនេះ បងស្រីម្នាក់ហ្នឹងគាត់មកពីខាងស្រែអំបិល តែតាមពិតមិនមែនជាប្រធានសហករណ៍ទេ គាត់ម៉ោដល់គាត់ចង់ធ្វើប្រធានសហករណ៍ទៅ ហើយបានគាត់ថាគាត់សួរមិត្តនារីថាមិត្តនោះ គាត់មកធ្វើអីប៉ុនតាមពិតគាត់ដឹងហើយគាត់ ជួបជាមួយខ្ញុំរួចហើយ អត់មានឲ្យធ្វើអីទេ ឲ្យគាត់សរសេរបញ្ជីមួយរយៗ ប្រជុំហើយប្រ ធានកងម៉ោប្រជុំរាល់ថ្ងៃ ឥឡូវអត់ទេណា៎មិនឲ្យគាត់ធ្វើទៀតទេគាត់ប្រាប់មិត្តនារីថាអត់ឲ្យ ហើយបានខ្ញុំស្តាប់បានអញ្ចឹងខ្ញុំដើរចេញឲ្យឆ្ងាយដល់ក្រោយមកទៀតបានឮបងមួយគាត់ថាបងអត់ទេ បងឯងត្រូវធ្វើប្រធានខ្ញុំ ប៉ុនមិនទេបងឯងត្រូវធ្វើប្រធានខ្ញុំ អេស៎ធ្វើប្រធានអីខ្ញុំមិនដឹងទេខ្ញុំមិនចេះធ្វើទេ ដល់ហើយគេមានគ្នាគេពីរនាក់ចុះ២ឃុំមិនមកនៅមន្ទីរនេះតែមួយមិនចឹងអេស៎!

ដានី ៖ បាទ!

ហ៊ិន ៖ ដល់ម៉ោគេពីរនាក់ហ្នឹងគេចេញទៅណា គេថាឲ្យធ្វើប្រធានវិញឲ្យធ្វើប្រធាន៣ថ្ងៃ ។

ដានី ៖ ប្រធានអីគេហ្នឹង?

ហ៊ិន ៖ ប្រធានមន្ទីរ បើគិតទៅវាជាសាខារបស់ស្រុកមួយហើយណាស់ វា២ឃុំទទួលខុសត្រូវ២ឃុំ

ដានី ៖ ឃុំនៅណា?

ហ៊ិន ៖ ឃុំនីពេជ្រ នឹងឃុំទួលគ្រើ ២ឃុំហ្នឹងឯង ។

ដានី ៖ ហ្នឹងឆ្នាំ៧៨ហើយ?

ហ៊ិន ៖ ឆ្នាំ៧៨ហើយ ខែ៨ ខែ៩ ឆ្នាំ៧៨ហើយថានៅបានប៉ុន្មានខែ ព្វខ្ញុំថាបានប៉ុន្មានខែហ្នឹងរត់ម៉ោនេះវិញបណ្តោយ ហើយខ្ញុំគិតថាដល់ពេលសភាពការណ៍ច្របូកច្របល់ខ្ញុំនៅហ្នឹងដែល គាស់ម៉ោនៅហ្នឹងដល់ពេលអញ្ចឹងសភាពការណ៍ច្របូកច្របល់អញ្ចឹងពួកនៅហ្នឹងគេអ្នករៀប ចំ ២នាក់ដែលខ្ញុំថា គេរត់បាត់អស់ហើយមិនដឹងគេទៅណា ហើយនៅតែខ្ញុំដល់ហើយមាននារីក្មេងៗយុវជនយុវនារីនៅច្រើននៅជាមួយប្រហែល១០នាក់មិនដឹងទេកាលហ្នឹង ច្រើនដល់ហើយខ្ញុំថាមិត្តឯងនាំគ្នាទៅផ្ទះទៅសម្បែងវិញទៅ មិត្តឯងនៅណាភូមិណាទៅវិញទៅ ព្រោះសភាពការណ៍ឥឡូវវាបែកបាក់គ្នាមិនដឹងទាក់ទងអ្នកណា ព្រោះមើលបង២នាក់នេះបាត់ហើយមិនដឹងទៅទាក់ទងណា ហើយឥឡូវទៅៗហើយមានអីយកទៅយកម៉ារបស់យើងបានហើយ កុំឲ្យយករបស់រួម ព្រោះនៅក្នុងមន្ទីរមានរបស់រួមមានក្រណាត់មានអីច្រើនស្អីៗនៅក្នុងមន្ទីរនេះបានចែកទៅតាមសហករណ៍ទៅតាមកង ហើយទឹមដឹកចូលម៉ោទៅដឹកឡើងប៉ុន្មានថ្ងៃចូលម៉ោច្រើនព្រោះមន្ទីរវាធំ ហើយមានកងសិប្បកម្ម មានកាត់ដេ មានអ្វីច្រើនកន្លែងណាស់ ទៅៗយកតែរបស់យើងទៅបើគ្មានរបស់អីទេ ទៅតែខ្លួនបានហើយ ខ្ញុំទៅប្រាប់ខាងសិប្បកម្មហ្នឹងណា៎!

ដានី ៖ បាទ!

ហ៊ិន ៖ ខាងនារីកាត់ដេខ្ញុំទៅប្រាប់ថាក្រណាត់កាត់ដេច្រកការុងច្រកបាវទុកទៅ កុំឲ្យយកកុំឲ្យប៉ះពាល់របស់រួម រៀបចំខ្លួនទៅហើយវិលត្រឡប់ទៅផ្ទះវិញទៅ ព្រោះសភាពការណ៍នៅនេះមិនដឹងទាក់ទងណាទេ ដល់អញ្ចឹងទៅស្រាប់តែបានមួយថ្ងៃ បែកគ្នាទៅៗផ្ទះអស់ទៅ បានមួយយប់ស្អែកឡើងស្រាប់តែប្រជាជនបរទេសម៉ោដឹកយកអាណាយកអីយកទៅ ដល់អញ្ចឹងខ្ញុំអង្គុយមើលអាណាយកអីយកទៅខ្ញុំមិនដឹង ។

ដានី : ចុះអ៊ំកាលពីអ៊ំនៅកងវរយ នៅកន្លែងកងចល័តអ៊ំមានធ្លាប់ជួយអ្នកដែលនៅកងចល័តជាមួយ អ៊ំដូចថាអ្នកនៅក្នុងមានមុខសញ្ញាអីដែលត្រូវគេចាប់ អ៊ំមានធ្លាប់ជួយគេឲ្យបានរួចផុត?

ហ៊ិន : បើគិតទៅខ្ញុំនៅរយៈពេលប្រហែល៦ខែ ប្រហែលជាមិនដល់៦ខែទេ ប្រហែល៦ខែអត់ទេ មិនដែលមានបញ្ហាទេ ។

ដានី : អត់ដែលបញ្ហា អត់ដែលមានជួយអីអ្នកណា?

ហ៊ិន : អត់ទេ!អត់ដែលមានទេ កាលនោះវាដូចបើតាមពិតគេថាទៅប្រោសសំអាតពួក១៧អីដែល ជាប់ខ្សែដូចរួចផុតអស់ហើយ មិនទាន់មានចំរេញមានអី ។

ដានី : ចុះអ៊ំកាលហ្នឹងម៉េចបានជាគេចាប់ដូចថាមេៗ ដូចជាមេរបស់អ៊ំឈ្មោះដូរអី អ្នកផ្សេងៗ ទៀតម៉េចបានគេចាប់?

ហ៊ិន : មិនដឹងដែរ ព្រោះចាំមើលដែលខ្ញុំស្គាល់មេៗដែលខ្ញុំធ្លាប់នៅជាមួយដូចជាបងហឿន បងអី មួយទៀតទេ ២នាក់ ហើយដូ គេចាប់ ហើយឈ្មោះខាត់មួយទៀតក៏គេចាប់ដែរ ។

ដានី : គេចាប់មូលហេតុអី?

ហ៊ិន : មិនដឹង ខ្ញុំអត់ដឹងដែរ ។

ដានី : ចុះកាលហ្នឹងអ៊ំអត់ដឹងម៉េចអ៊ំខ្លាច?

ហ៊ិន : ចុះយើង ដូចថាខ្ញុំនៅជាមួយប្អូនឯង ពេលគេចាប់ប្អូនឯងទៅច្បាស់ជាឆ្លើយដាក់ហើយ គេ សួរថាអ្នកណាៗខ្លះ អាហ្នឹងខ្លាចអញ្ចឹងទេ គ្មានខ្លាចអីទេខ្លាចតែអញ្ចឹងឯង ចាំមើលខ្ញុំនៅជា មួយបងហឿនគេចាប់បងហឿន ប៉ុន្តែខ្ញុំនៅជាមួយគាត់ គាត់គ្រប់គ្រងប៉ុនខ្ញុំធ្វើការងារ ផ្សេង ។

ដានី : ហឿនគាត់គ្រប់គ្រងអីគេ?

ហ៊ិន : ហឿនគណៈស្រុកៗកំពង់ស្វាយ ។

ដានី : ចុះអ្នកណាគេឈ្មោះសុង?

ហ៊ិន : សុងគណៈស្រុក នោះកាលពីជំនាន់សង្គ្រាម ហឿននេះក្រោយចប់សង្គ្រាមហើយ ហើយ ឈ្មោះអីទៀតទេ ២នាក់ខ្ញុំធ្លាប់នៅជាមួយគាត់ កាលមុនខ្ញុំនៅជាមួយគាត់ខ្ញុំនៅបានបន្តិច ទេ បាន៣ខែទេគេចាប់ដែរ ។

ដានី : ដល់ពេលគេចាប់អ៊ំដឹងគេចាប់ កាលហ្នឹងយើងឃើញគេចាប់?

ហ៊ិន : អត់ទេ គ្រាន់តែដឹងតាមគេ ឧទាហរណ៍ថាខ្ញុំស្គាល់ប្អូនឯង ប្អូនឯងនៅជាមួយគាត់អញ្ចឹង ដល់ហើយគេនេះទៅ ចុះអាបាត់បងទៅណាដូចមិនដែលឃើញ ហ៊ឺ!យកទៅបាត់យូរហើយ

ដានី ៖ ដល់ពេលគេចាប់ទៅគេមានអ្នកថ្មីមកជំនួស?

ហ៊ិន ៖ ម៉ោជំនួស គេចាប់តាស្អីទេខ្ញុំភ្លេចឈ្មោះហើយ បានតាហឿននេះមកជំនួស ហើយខ្ញុំទៅនៅជាមួយតាហឿននេះទៀត ទៅនៅកាលនោះដូចខ្ញុំមិនទាន់មកគ្រប់គ្រងកងចល័តនេះទេ នៅអាជីកអន្លង់ជីកអីទៅឲ្យកងចល័តគេលើកអាងត្រពាំងថ្ម អាង១មករានៅហ្នឹងទៅស្រាប់ពួកគេ ចាប់ចុះ១០ថ្ងៃគេមិនសម្រាក់ម្តង កងចល័តគេសម្រាក់១មករា នៅឯពុកយុកនោះ

ដានី ៖ បាទៗ!

ហ៊ិន ៖ គាត់នៅហ្នឹងឯង ដល់១០ថ្ងៃខ្ញុំមកលេងគាត់ម្តង ។

ដានី ៖ អ៊ំមានឃើញគេចាប់ផ្ទាល់ភ្នែកទេ?

ហ៊ិន ៖ អត់ទេៗ

ដានី ៖ ដល់ពេលអញ្ចឹងខ្លាចវិញ?

ហ៊ិន ៖ ពួខ្លាចៗគាត់ឆ្លើយដាក់ថាមានអ្នកណាអ្នកណាខ្លះនៅជាមួយខ្លះទេចេះតែភ័យៗទៅ ។

ដានី ៖ ចុះមិនដែលធ្លាប់ពីណាដែលនៅក្នុងក្រុម នៅក្នុងកងជាមួយអ៊ំអីត្រូវគេចាប់ មានបញ្ហាអីអ៊ំអត់ជួយអីអត់ដែលមានទេ?

ហ៊ិន ៖ មាន ប៉ុនមាននោះមានតាំងពីជំនាន់យើងនៅសង្គ្រាមម៉្លេះ ឆ្នាំ៧២អាហ្នឹងខ្ញុំធ្លាប់ជួយបាន២នាក់ដែរ ។

ដានី ៖ ជួយរឿងអី?

ហ៊ិន ៖ កាលហ្នឹងជួយរឿងនេះ ចាំមើលខ្ញុំគេឲ្យចុកមកឃោសនាតាមភូមិ មកបំផុសប្រជាជនឲ្យគាំទ្ររណសិរ្សរំដោះជាតិ មកប្រជុំប្រជាជនឲ្យយល់ដឹងសភាពការណ៍កិច្ចការប្រទេសជាតិយើងយ៉ាងម៉េចៗ ដីប្រជុំទៅដល់ហើយគេចោទគាត់នោះឯងថាគិញរបស់លន់ ណល់ អាហ្នឹងខ្ញុំជួយ កាលខ្ញុំនៅរៀនកម្មករ កាលហ្នឹងគាត់ជម្លៀសពីកម្មករមកនៅនោះៗដល់ហើយគាត់ជម្លៀសមកនៅភូមិខ្ញុំ ហើយម្យ៉ាងគាត់ចិនគាត់មករកស៊ីនៅស្រុកខ្ញុំ ទៅដល់នោះគេចោទគាត់ថាធ្វើគិញឲ្យលន់ ណល់ គេចាប់ទៅ ហើយខ្ញុំទៅជួយយកមកវិញព្រោះខ្ញុំធ្លាប់ទៅនៅរៀននៅហ្នឹង ខ្ញុំធ្លាប់លេងជាមួយកូនគាត់នៅនោះទៅម៉ោដេកនៅស៊ីបាយនៅហ្នឹងញឹកញាប់ណាស់ ។

ដានី ៖ ជួយទៅយកគាត់មកវិញ?

ហ៊ិន ៖ ជួយទៅយកមកវិញរស់រហូតមកទល់ឥឡូវ ឥឡូវនៅរស់ ។

ដានី ៖ នៅណាទៅ?

ហ៊ិន ៖ នៅសានគរ

ដានី ៖ គាត់ឈ្មោះអី?

ហ៊ិន ៖ ឈ្មោះ ចន្ទវៀល កាលខ្ញុំទៅឆ្នាំ៩៨-២០០០ខ្ញុំទៅសួរគេ គេថានៅ ប៉ុនចាស់ហើយ ឥឡូវដឹងគាត់ខូចហើយក៏មិនដឹង ។

ដានី ៖ គេថាគិញលន់ ណល់?

ហ៊ិន ៖ គេថាគិញលន់ ណល

ដានី ៖ គេចាប់យកទៅដាក់នៅណា?

ហ៊ិន ៖ គេដាក់នៅនឹងភូមិស្មោញ ខាងភូមិនីពេជ្រ(ខ) ។

ដានី ៖ អ៊ំទៅយកមកវិញ?

ហ៊ិន ៖ បាទ!ខ្ញុំទៅសុំយកមកវិញ ខ្ញុំថាគាត់អត់អីទេ គាត់មិនមែនទេ គាត់អ្នកស្នេហាជាតិហើយ បានគាត់មិនរត់ទៅចូលនៅកំពង់ធំ ចូលលន់ ណល់ គាត់ម៉ោនៅនេះនៅជាមួយយើង ទៅ ចោទគាត់ថាគាត់គិញអីទៀត មិនមែនគិញអីទេគាត់អ្នករកស៊ីធម្មតាហ្នឹងមួយ ហើយមួយ ទៀតគាត់នេះកាលនៅពីសង្គមគាត់ធ្វើអាចារ្យលោក ហៅអាចារ្យបាលីគេនិមន្តមកបង្រៀន នៅភ្នំពេញនេះឯង ដឹផុតពីវត្តភ្នំពេញទៅគេនិមន្តទៅបង្រៀននៅវត្តបុទម ដល់ហើយអាវដ្ឋ ប្រហារឆ្នាំ៧០នេះទៅ គាត់ក៏សឹកទៅ ទៅយកប្រពន្ធ ប៉ុនហ្នឹងខ្ញុំជួយបានមួយដងហើយគេ ចាប់ទៅទាំងពីរនាក់នេះខ្ញុំទៅយកម៉ោទាំងពីរនាក់នេះ ដល់ក្រោយម៉ោដូចខ្ញុំថាឈប់ទៅ ខ្ញុំ ទៅនៅទ័ព ដល់ពេលដែលខ្ញុំវិលម៉ោនៅនឹងវិញ បានខ្ញុំសួរនាំទៅ បានបាត់ទៅ គេថាហ៊ឹគេ វ៉ៃចោលតាំង៧២ ។

ដានី ៖ ពីណាគេ?

ហ៊ិន ៖ ឈ្មោះអាចាវ សុខន កាលនោះខ្ញុំទៅដោះមកវិញ ហ៊ឹដោះមកវិញហើយក្រោយម៉ោគេ ចាប់យកទៅវិញទៀត ។

ដានី ៖ គាត់ខុសអីអាហ្នឹង?

ហ៊ិន ៖ មិនដឹងដែរ

ដានី ៖ ភូមិណា?

ហ៊ិន ៖ គាត់ហ្នឹងមិនដឹងអ្នកស្រុកណាទេ ប៉ុនគាត់បួស បួសទៅគាត់ចេះភាសាបាលី គេនិមន្តមក បង្រៀននៅសាលាបុទមដង មកបង្រៀននៅវត្តពេញនេះដង ទៅម៉ោៗក៏គាត់សឹកទៅក៏ យកប្រពន្ធអ្នកនីពេជ្រនេះទៅ ។

ដានី ៖ បាទ!

ហ៊ិន ៖ ប៉ុនវាអាចបែបអញ្ចេះដឹងតាមមើល ប៉ុនខ្ញុំឮគេនិយាយដែរទេណា ថាគេហាមពួកគាត់ របៀបចិនអ្នកជំនួយរកស៊ីពាណិជ្ជកម្មនោះណាទៅលក់ចេញទិញចូល អាចពាក់ពន្ធ័ចេះតាមមើល ចេញចូលលន់ ណល់ ដែរចេញចូលកំពង់ធំដែរនោះ

ដានី ៖ អញ្ចឹងអ៊ំបែក៧៥ហើយនៅខាងភស្ដុភានៅខាងដឹកជញ្ជូន?

ហ៊ិន ៖ ខ្ញុំគិតទៅនៅតាំងពីសម័យសង្គ្រាមម៉ោ នៅរហូតតាំងពីឆ្នាំ៧៤ហើយ ដែលខ្ញុំថាប្រុងគេបញ្ជូនទៅភ្នំពេញ ដល់កងទ័ពខ្ញុំរបួសអស់ទៅបានម៉ោនៅពាណិជ្ជកម្មវិញ នៅពាណិជ្ជកម្មដល់ចប់ទៅបានមកនៅភស្ដុភាវិញ ។

ដានី ៖ នៅភស្ដុភាពបានយូរដែល?

ហ៊ិន ៖ អត់ទេ!អត់យូរទេបានប្រហែលជា១ខែឬ២ខែមិនដឹងខ្ញុំភ្លេចហើយ បានម៉ោនៅកងចល័ត ។

ដានី ៖ ផុតពីកងចល័ត?

ហ៊ិន ៖ ចេញពីកងចល័តទៅ ទៅធ្វើនេសាទ ផុតនេសាទទៅ ទៅធ្វើខាងសិប្បកម្ម ធ្វើកញ្ចើរ ធ្វើចុះធ្វើអីៗរហូតទោដល់ឆ្នាំ៧៨ ។

ដានី ៖ ដល់ពេល៧៨ហ្នឹងបានម៉ោណាទៀត?

ហ៊ិន ៖ បានម៉ោនៅធ្វើលេខាគេនៅមន្ទីរ បើគិតទៅគេថាជាសាខាស្រុកមួយ ។

ដានី ៖ ស្រុកកំពង់ស្វាយ?

ហ៊ិន ៖ បាទ!ស្រុកកំពង់ស្វាយ ហើយបានខាងកងទ័ពមជ្ឈិមនេះ ដែលជូនវៀចូល៧មករា ខែ២បានកងទ័ពមកដល់ ហើយខ្ញុំអត់ម៉ោ ខ្ញុំនៅចេះតែដើរគេចខ្លួនៗនៅនោះ ប៉ុនខ្ញុំមានកម្លាំងចុះបើក្មេងៗចេះតែសុំម៉ោនៅជាមួយទៅខ្ញុំ ខ្ញុំចេះតែមានកាំភ្លើងមានអីឲ្យវាស្ពាយវាកាន់ទៅណា៎ដើម្បីឲ្យវាការពារ ដូចការពារខ្ញុំ ខ្ញុំចេះតែខបត្ដមហើយបានកងទ័ពមជ្ឈិម ។

ដានី ៖ ពីណាគេកងទ័ពមជ្ឈិម?

ហ៊ិន ៖ ឈ្មោះលោក ឈិតៗនៅខាងព្រំដែនយួន នៅក្រចេះគាត់នៅកងទ័ពមជ្ឈិមគាត់នៅឈរជើងនៅក្រចេះ ពីខែ២បានគាត់មកដល់ មកដល់ខ្ញុំនេះបានខ្ញុំទៅកងជាមួយគាត់ទៅ ខ្ញុំគិតថាទំនាក់ទំនង គាត់ចង់សួរនាំមើលទៅមិនកើតទេខ្ញុំខ្ជិលដែល ខ្ញុំគិតថាចាប់ពីពេលនេះតទៅឈប់ចូលក្នុងគុកនយោបាយទេ ប៉ុនបើសិនណាជាមិនម៉ោក៏មិនរស់តាមមើល ។

ដានី ៖ ម៉េចអញ្ចឹង?

ហ៊ិន ៖ ព្រោះវាមិនរស់វានិន្នាការ ទោះយើងមិនធ្វើអីក៏ដោយ ក៏យើងនៅក្នុងហ្នឹងដែរ ។

ដានី ៖ អ៊ូ! បានន័យថាបើសិនយើងអត់បានចូលជាមួយ នៅខាងពេលដែលវៀតណាមចូលម៉ោ ។

ហ៊ិន ៖ បើសិនណាជានៅផ្ទះខ្ញុំ គិតថាខាងណាក៏អត់ចូលដែរ តែខាងវៀតណាមក៏មិនចូល គិតនៅជាប្រជាជនធម្មតាខ្ញុំគិតថាអញ្ចឹង ។

ដានី ៖ ចុះម៉េចគិតថាមិនរស់?

ហ៊ិន ៖ បើយើងមិនចូលជាមួយគេហ្នឹង មុខជាគេវៃប្រជាជនគេវៃ គេសម្លាប់ហើយ ។

ដានី ៖ ហេតុអីបានជាគេវៃ?

ហ៊ិន ៖ ចុះយើងពួកគាត់ហ្នឹងហើយរបបពាឆ្នាំ៨ខែ២០ថ្ងៃហ្នឹងណា ។

ដានី ៖ អ៊ូ! ខ្ញុំយល់ដូចថាអីពួកកម្មាភិបាលហ្នឹង?

ហ៊ិន ៖ បាទ! ហ្នឹងហើយ គេមើលឃើញយើងជាកម្មាភិបាល តែតាមពិតយើងមិនបានធ្វើអីទេ គ្រាន់តែគេប្រើទេ ជាឧបករណ៍គេប្រើ ។

ដានី ៖ ដល់អញ្ចឹងអ៊ំទ្រូទ្រូសហើយម៉េចទៀត?

ហ៊ិន ៖ ដល់ម៉ោជួបនឹងគាត់ គាត់ថាឥឡូវគាត់និយាយដូចខ្ញុំថាអញ្ចឹង គាត់ថាឥឡូវអង្គការឲ្យទៅខាងនោះហើយទៅភ្នំវៃចាប មើលឃើញពីកំពង់ធំម៉ោ ខាងខ្ញុំគេហៅភ្នំពពួកវិលទេ ប៉ុនបង ឈិតៗនេះ ហ៊ីភ្នំឱរាល ភ្នំវៃចាបគេថា ហើយថាហ៊ីទៅមិនបានទេបង ទី១ ផ្លូវ ទី២ ទឹក ទី៣ ស្បៀង បងឯងមើលឃើញហើយណាស់ដើរយ៉ាងតិចកន្លះខែខ្ញុំថាអញ្ចឹង អញ្ចឹងទៅ ណាទៅៗទៅផ្លូវលើទៅខ្ញុំមានពូម្នាក់ស្គាល់ផ្លូវម៉ោព្រំដែនស៊ីម កាលហ្នឹងថៃហៅព្រំដែន ស៊ីម ថៃកាលហ្នឹងហៅស៊ីម ប៉ុនស្លាប់ហើយឥឡូវ គាត់ធ្លាប់រកស៊ីចេញចូលព្រំដែនស៊ីម នៅឯអន្លង់វែង បានគាត់នាំម៉ោកម្លាំងតិចទៅកម្លាំងកងទ័ពតែ៣០០០ទេកាលហ្នឹង ដល់ចេះតែម៉ោពួកអ្នកដាច់ប៉ែកពីកងផ្សេងៗអង្គភាពផ្សេងៗចេះតែម៉ោៗដល់បន្ទាយឆ្មា ថ្មពួកនេះ៦ពាន់ ម៉ោសល់នេះទាំងអស់ ម៉ោដល់នេះឯងបានជួបអង្គការហើយ ។

ដានី ៖ ជួបពីណាអង្គការ?

ហ៊ិន ៖ ដឹងៗពីណាអង្គការហើយ

ដានី ៖ ចុះអ៊ំអត់បានជួបអង្គការទេ?

ហ៊ិន ៖ អត់ៗទេញុំតែគេថាទេ

ដានី ៖ ចុះអ៊ំកាលហ្នឹងដល់ពេលយើងរត់ម៉ោអញ្ចឹង មានកងទ័ពអញ្ចឹងអ៊ំអត់មានតួនាទីអី?

ហ៊ិន ៖ អត់ទេខ្ញុំអត់មានតួនាទីទេ បើគិតថាមេក្រុមចុះ មានគ្នាប៉ុន្មាន៨-១០នាក់ដែរនៅគ្នា១ក្រុម ប៉ុនដឹងអាណាមេអាណាកូន ប៉ុនគេគោរពខ្ញុំព្រោះធ្លាប់នេះអញ្ចឹងគេនៅតែគោរពអញ្ចឹង ។

ដានី ៖ ចុះអ៊ំមួយទៀតកាលហ្នឹងដូចថាអ៊ំដឹងថាយើង បើសិនជាអ៊ំចូលម៉ោខ្លាចប្រជាជនសម្លាប់ព្រោះយើងធ្លាប់ជាកម្មាភិបាលអញ្ចឹង កាលជំនាន់ហ្នឹងអ៊ំដែលឃើញគេចាប់គេសម្លាប់ប្រជាជនអីអ៊ំមានដែលឃើញទេ?

ហ៊ុន ៖ មិនដែលឃើញទេ

ដានី ៖ ហើយអ៊ំដឹងដែរឬអត់?

ហ៊ុន ៖ អត់មិនដែលដឹងទេ

ដានី ៖ ចុះបើអ៊ំអត់ដឹងម៉េចក៏អ៊ំខ្លាច ខ្លាចគេសម្លាប់?

ហ៊ុន ៖ ចុះបើពួកគេចាប់ ដូចខ្ញុំនិយាយអញ្ចឹងបើនៅជាមួយ ហៀនគេចាប់ហៀន នៅជាមួយដូគេចាប់ដូ ។

ដានី ៖ ចុះប្រជាជនអ្នក១៧មេសា ពួកកងចល័តគេចាប់អញ្ចឹងដែរ?

ហ៊ុន ៖ អត់ទេ ខាងខ្ញុំដូចជាអត់ទេអាការកាប់សម្លាប់មិនមានទេ

ដានី ៖ អត់មានទេ?

ហ៊ុន ៖ ព្រោះខាងខ្ញុំតាមពិតណាស់គេហៅថាភូមិរំដោះ មិនដែលមានពាក់ព័ន្ធរឿងការ គេហៅថាខ្មាំងណា៎របបនយោបាយលន់ ណល់នោះមិនបានធ្វើប៉ូលីសធ្វើទាហានអីទេ ។

ដានី ៖ ចុះអ៊ំមានអ្នកផ្សេងដូចថាកម្មាភិបាលផ្សេងៗទៀតនៅក្នុងភូមិហើយត្រូវប្រជាជនសម្លាប់អីមានដែលឬអត់?

ហ៊ុន ៖ ណែ៎!មាននៅឃុំទួលគ្រៀនេះមានគេសម្លាប់២នាក់ ធ្លាប់ធ្វើប្រធានកង នៅនោះម៉ាកងមានវាមានពេងបាយ១

ដានី ៖ គេហៅសហករណ៍?

ហ៊ុន ៖ ហ្នឹងហើយគេហៅសហករណ៍ សហករណ៍ម៉ាឃុំគេហៅសហករណ៍ ហើយបានជាគេបំបែកទៅកងធំ ម៉ាកងធំមានឆ្នាំងបាយរួម១ ២នាក់ហ្នឹងម៉ោមានអីប្រជាជនរួមរឹងាប់ស្លូក ។

ដានី ៖ យ៉ាងម៉េចបានប្រជាជនរឹ?

ហ៊ុន ៖ ចុះគេខឹងមិនឲ្យស៊ីបាយឆ្អែតនោះមិនឲ្យគេស៊ីបាយឲ្យគេស៊ីបបរទី១ ទី២គឺឲ្យគេធ្វើការនឿយពេក ដីកប្រឡាយ លើកទំនប់ ។

ដានី ៖ ចុះម៉េចបានអត់ឲ្យគេហូបបាយឆ្អែតហើយឲ្យធ្វើការនឿយ តើអ៊ំដឹងគោលនយោបាយគេពេលហ្នឹងដែរឬអត់?

ហ៊ុន ៖ មិនដឹងទេ!ព្រោះខ្ញុំនៅនេះមិនដែលហូបបបរផងហ្នឹង ។

ដានី ៖ អ៊ំហូបគ្រប់គ្រាន់ទេ?

ហ៊ុន ៖ បាទ!ហូបគ្រប់គ្រាន់

ដានី ៖ ចុះអ៊ំកាលហ្នឹងអ៊ំមានគ្រួសារឬនៅ?

ហ៊ុន ៖ មានហើយ ខ្ញុំមានឆ្នាំ៧០ នេះគ្រួសារក្រោយទេនេះ

ដានី ៖ អ៊ូ!គាត់គ្រួសារក្រោយទេ?

ហ៊ុន ៖ បាទ!គ្រួសារមុនបានកូន៤នាក់ កាលដែលខ្ញុំ៧៩រត់ម៉ោនៅទេ ដល់ពេលនេះទៅតាមរកខ្ញុំតាមរកទៅម៉ោៗចេះតែតាមរកៗក៏គ្រុនចាញ់ស្លាប់ទៅ បានឆ្នាំ១៩៨៣បានគេដឹងដំណឹងថាខ្ញុំនៅភ្នំឆ័ត្រ កាលមុនខ្ញុំនៅភ្នំឆ័ត្រ ។

ដានី ៖ បាទ!

ហ៊ុន ៖ ដ៏មកដល់នេះគេចែកគ្នាខ្ញុំត្រូវទៅនៅភ្នំឆ័ត្រវិញ នៅកងពល៣១៩

ដានី ៖ អញ្ចឹងគ្រួសារអ៊ំមុនគាត់ស្លាប់នៅឆ្នាំណា?

ហ៊ុន ៖ ស្លាប់នៅឆ្នាំដូច៨២-៨៣ ។

ដានី ៖ បានមកជួបអ៊ំដែរឬអត់?

ហ៊ុន ៖ អត់ទេៗអត់បានជួបទេ មានអ្នកទី២នេះម៉ោជួប ។

ដានី ៖ ចុះកូន?

ហ៊ុន ៖ កូនម៉ោ១ រាល់ថ្ងៃនេះកូនមុនម៉ោនៅជាមួយបានប្រពន្ធហើយ

ដានី ៖ ហើយ៣នាក់ទៀត?

ហ៊ុន ៖ ស្លាប់អស់ហើយ ស្លាប់២នាក់ នៅសល់២ អានេះអាពៅម៉ោនៅតាំងពីផ្ដាច់ខ្លួនហើយធ្វើសមាហរណកម្មហើយម៉ោនៅលីវទើមបានប្រពន្ធនៅនេះ ។

ដានី ៖ ចុះមួយទៀតនៅណា?

ហ៊ុន ៖ នៅស្រុកបង អាបងនៅស្រុករាល់ថ្ងៃនេះ ហើយ២នាក់ទៀតស្លាប់ ៤នាក់ស្លាប់២នាក់នៅសល់២នាក់ ។

ដានី ៖ ចុះប្រពន្ធអ៊ំគាត់ធ្វើអីដែរ?

ហ៊ុន ៖ អត់មានធ្វើអីទេ ធ្វើពោតនៅតែផ្ទះនៅជាមួយម៉ែឪខ្ញុំ ។

ដានី ៖ ចុះអ៊ំពេលដែលគេចាប់អ៊ំរត់ទៅនេះអ៊ំរត់ទៅនោះទៅនេសាទអីហ្នឹងតើប្រពន្ធកូនអ៊ំមានទៅជាមួយដែរឬអត់?

ហ៊ុន ៖ អត់ទេៗនៅជាមួយឪនៅជាមួយម៉ែជាមួយឪ ដល់ម៉ែគាត់តាមរកៗបានដឹងដល់៨៣ហើយ

មុននឹងរដ្ឋកម្ពុជាវ៉ៃបាក់ភ្នំឆត្រ វៀតណាមវ៉ៃបែកបាក់ភ្នំឆត្រនេះ មុនប្រហែលជាមួយខែ បានមានអ្នកបំរើម្ដាយខ្ញុំមកប្រាប់ថាគ្រួសារខ្ញុំស្លាប់ហើយ ហើយមិនបាច់ទៅវិញទេ មានកន្លែងណារស់នៅស្រួលរស់នៅទៅ ដល់ហើយបានយកគ្រួសារក្រោយ ។

ដានី ៈ យកគ្រួសារក្រោយឆ្នាំណាទៀតទៅ?

ហ៊ិន ៈ ប្រហែលឆ្នាំ៨២-៨៣ហ្នឹងឯង អ៎៨២ឬ៨០ភ្លេចហើយ ប្រពន្ធឆ្លើយថាឆ្នាំ៨០ ។

ដានី ៈ ចុះអ៊ីកាលហ្នឹងអ៊ីម៉ោជួបនឹងឆាតដែលគាត់មេទ័ពហ្នឹងជួបទៅគាត់បបួលមៅភ្នំដងរែក ម៉ោភ្នំចាបពេលហ្នឹងអ៊ីដើរយ៉ាងម៉េចទៅ?

ហ៊ិន ៈ ដើរម៉ោដើរជាមួយកងទ័ព

ដានី ៈ មកដល់ណាទៅ?

ហ៊ិន ៈ ម៉ោដល់នេះឯង ជូនគាត់មកដល់នឹងកន្លែង ប៉ុននៅដីថៃកាលហ្នឹងនៅដីថៃ

ដានី ៈ គេហៅអីទៅថៃ?

ហ៊ិន ៈ កន្លែងដីថៃហ្នឹងគេហៅវត្តគាង ។

ដានី ៈ ឆ្នាំណាទៅមលដល់?

ហ៊ិន ៈ ឆ្នាំ៧៩ខែ៤មកដល់ ។

ដានី ៈ មកដល់ជាមួយពីណាខ្លះកាលហ្នឹង?

ហ៊ិន ៈ ខ្ញុំកាលហ្នឹងម៉ោគ្នាច្រើនណាស់

ដានី ៈ ម៉ោដល់ដំបូងជួបពីណាខ្លះទៅ?

ហ៊ិន ៈ ម៉ោដល់នេះជួប ចាំមើលកាលរត់បែកបាក់គ្នា ខ្លះគេរត់ម៉ោខាងនេះទៅ ខ្លះរត់ម៉ោខានេះ ម៉ោក៏ជួបជុំគ្នានៅនេះ ម៉ោដល់ពូថា អ្នកដែលគេបានទៅប្រជុំគេមកផ្សព្វផ្សាយថាយើងជួបអន្តការហើយ ឥឡូវពួកយើងគេឲ្យទៅនៅខាងជើងផ្លូវជាតិលេខ៥វិញទៅនៅភ្នំឆត្រ ដល់ខែ៨បានទៅដល់ភ្នំឆត្រខែ៨ ឆ្នាំ៧៩ នៅភ្នំឆត្ររហូតដល់ខែ៣ឆ្នាំ៨៣បានវៀតណាមវ៉ៃបំបែកភ្នំឆត្រហ្នឹងបានរត់មកនេះវិញ ។

ដានី ៈ បាទ!កាលទៅភ្នំឆត្រមានជាអន្តភាពមានជាកងពលអីដែលអត់?

ហ៊ិន ៈ បាទ!មានៗ

ដានី ៈ គេកងពលអីគេ?

ហ៊ិន ៈ គេហៅកងពល៥១៩

ដានី ៈ ពីណាគេប្រធាន?

ហ៊ិន ៖ ប្រធានឈ្មោះតា យន គាត់ស្លាប់ហើយតាយន ។

ដានី ៖ តាយន ហ្នឹងគាត់ធ្វើអីកាលពីសម័យ៣ឆ្នាំ?

ហ៊ិន ៖ កាលសម័យ៣ឆ្នាំកងទ័ពដែរ ។

ដានី ៖ កងទ័ពនៅណា?

ហ៊ិន ៖ អត់ដឹងដែរមិនដឹងទៅនៅណា ។

ដានី ៖ គាត់ស្លាប់ឆ្នាំណាតាយន?

ហ៊ិន ៖ គាត់ស្លាប់កាលយើងធ្វើសមាហរណកម្មហើយ គាត់ជាន់មីនស្លាប់ គាត់ឈប់នៅ៥១៩ គាត់ទៅនៅខាងសំឡូតទៅនៅជាមួយសុជាតនៅសំឡូតហើយក៏ជាន់មីនស្លាប់ ។

ដានី ៖ បាទ! ហើយម៉េចទៀតទៅដល់ពេលបែកភ្នំឆត្រហើយ?

ហ៊ិន ៖ បែកភ្នំឆត្រម៉ោរត់ម៉ោនេះ ប៉ុនកងទ័ពនៅនោះដដែលនៅភ្នំឆត្រដដែល ប៉ុនប្រពន្ធកូនអីម៉ោនេះ ។

ដានី ៖ អ៊ូ! ប្រពន្ធកូនម៉ោនេះ?

ហ៊ិន ៖ បាទ! ហើយខ្ញុំនៅឯឃ្លាំងនៅភស្តុភា ដល់ហើយខ្ញុំរត់ម៉ោតាមប្រពន្ធម៉ោ ។

ដានី ៖ រត់ទៅម៉ោម៉េចទៅ?

ហ៊ិន ៖ ម៉ោដល់ម៉ោនៅនេះឯង ដល់ឆ្នាំ១៩៨៥ រដ្ឋកម្ពុជាវៃបែក បានរត់ទៅនៅសាយអេច ទៅនៅភ្នំតាង៉ុក បានខាងនោះបានអ្នកដឹកនាំម្តងនេះគេឈប់ហៅគេហៅកម្ពុជាប្រជាធិបតេយ្យ អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យហ្នឹងដឹកពួកខ្ញុំទៅនៅ៨៥ គេហៅទៅនៅនឹងដីថៃនៅជុំថងនៅនេះខាងលិចចំ នៅពីឆ្នាំ១៩៨៥ទល់មកឆ្នាំ៩០ បានមកនៅនេះវិញ ហើយកាលនៅនោះខាង៥១៩ចេះតែទាមទាឲ្យខ្ញុំទៅវិញ ព្រោះខ្ញុំជាសមាជិកគេខាងនោះ ប៉ុនខាង១០២ នៅនេះនៅម៉ាខ្សែនេះគេហៅ១០២ ពួក១០២ខ្ញុំមានមិត្តភក្រ័ស្គាល់គ្នាខាង១០២ព្រោះគាត់ដឹងថាខ្ញុំចេះ ។

ដានី ៖ បាទ!

ហ៊ិន ៖ ចេះអក្សរចេះលេខគ្រាន់បើ ឃើញអត់មានគ្រូបង្រៀនគាត់យកឲ្យខ្ញុំធ្វើគ្រូបង្រៀនតាំងពីឆ្នាំ១៩៨៥រហូតដល់ឆ្នាំ៩៣ ។

ដានី ៖ ធ្វើគ្រូបង្រៀនអីទៅ?

ហ៊ិន ៖ បង្រៀនលេខបង្រៀនអក្សរ?

ដានី ៖ អ៊ូ! បង្រៀនកូនសិស្ស?

ហ៊ិន : បាទ!បង្រៀនកូនសិស្ស ពេលដល់ឆ្នាំ១៩៩៣មិនជំនាន់អ៊ុន តាក់នោះ?

ដានី : បាទៗ!

ហ៊ិន : គេបោះឆ្នោតទៅខ្មែរក្រហមមិនធ្វើពិធីការចូលរួមក្នុងការបោះឆ្នោត

ដានី : បាទ!

ហ៊ិន : ដល់ហើយពេលបោះឆ្នោតទៅ គេចាត់ទុកពួកខ្មែរក្រហមជាពួកខុទាមពួកក្រៅច្បាប់គេមិនវ៉ៃ ដ៏វ៉ៃខាងកងពលយើងខាង១០២កងពលម៉ាឡៃមានសុខភាពហើយនឹងវ៉ាន់ សុផាត ខ្ញុំចាំ ច្បាស់ ខ្ញុំកាលហ្នឹងនៅបង្រៀនក្មេង ចុះក្មេងព្រឹកឡើងមានណាគ្រូគេ មានដែលគ្រូច្រើន ប៉ុន្មានអាខ្លះម៉ោកូនឈើអាខ្លះប្រពន្ធ ខ្ញុំនេះកូនប្រពន្ធមិនសូវឈឺទេ មានតែខ្ញុំទៅបង្រៀនឲ្យ វាស់ៗល្ងាចនៅសាលានោះ ដល់ហើយថ្ងៃនោះឯងគេវ៉ៃខ្លាំងណាស់គេវ៉ៃម៉ោដល់ ចូលម៉ោ ឃើញផ្លូវកន្លែងទួលទំរអាផ្លូវក្លែងកែងនេះ ។

ដានី : បាទ!

ហ៊ិន : វ៉ៃជិតដល់នេះ ដល់ហើយសុខភាពហើយនឹងវ៉ាន់សុផាតហ្នឹងម៉ោហេស៊ីបង្រៀនដល់ណា ទៀតស្រុកសង្គ្រាមប៉ុននេះទៅហើយឥឡូវបង្រៀនអុះយកដីសទៅតាម ឥឡូវឈប់រៀន ហ្នឹងហើយ ដល់ហើយឈ្មោះ ភេនៗនោះគាត់ធ្លាប់ធ្វើប្រធានខ្ញុំកាលឆ្នាំ៨៥គាត់ម៉ោ គាត់ ថាចេះ ឯងឈរឈ្មោះមួយធ្វើឃុំនឹងគេទៅ ខ្ញុំក៏គិតថាអ៊ើបើមេគេថាអញ្ចឹងក៏ធ្វើដែរ ហើយក៏ឈរឈ្មោះទៅបានជាប់ឃុំម៉ោរហូតម៉ោ ។

ដានី : តាំងពីឆ្នាំណាម៉ោ?

ហ៊ិន : ឆ្នាំ៩៣រហូតដល់៩៦យើងធ្វើសមាហរណកម្ម ការពិត៩៦ខែ៨យើងធ្វើសមាហរណកម្ម ចូលជាមួយរដ្ឋាភិបាល ៩៧បានមានអនុក្រឹតទទួលស្គាល់ស្រុកម៉ាឡៃមិនចឹង?

ដានី : បាទ!

ហ៊ិន : សំពៅលូន ភ្នំព្រឹក កំរៀងហូរហែរមានប៉ៃលិនហ្នឹងហើយ ហើយបានធ្វើមេឃុំរហូតដល់ឆ្នាំ ប៉ុន្មានបោះឆ្នោតក្រុមប្រឹក្សាឃុំដូចជាឆ្នាំ២០០២ ?

ដានី : បាទៗ!

ហ៊ិន : ២០០២ហ្នឹងហើយក៏បង្កើតជាក្រុមប្រឹក្សាឃុំទៅ ដល់ពេលបោះឆ្នោតឆ្នាំ២០០៨ក៏គេឲ្យ ធ្វើក្រុមប្រឹក្សាស្រុកទៀតជាប់រាល់ថ្ងៃ ។

ដានី : បាទ!អញ្ចឹងអ៊ំម៉ោជាមួយអ៊ំស្រីម៉ោដល់ម៉ាឡៃដំបូងពេលបែកភ្នំឆត្រឆ្នាំ៨៣អី?

ហ៊ិន : បាទ!

ដានី ៖ ម៉ោដល់ដំបូងគេធ្វើអីទៅម៉ោដល់?

ហ៊ិន ៖ ម៉ោដល់នេះគេឲ្យជីកដញ្ចូនលីគ្រាប់លីអង្ករឲ្យកងទ័ពនៅ

ដានី ៖ មានផ្ទះមានសម្បែងទេកាលហ្នឹង?

ហ៊ិន ៖ អត់ទេ!អត់មានទេ ចុះកាលហ្នឹងទឹមមានកូន១នាក់ មានអង្រឹង៣ អង្រឹងកូន១ អង្រឹងឪ១ អង្រឹងម៉ែ១ ។

ដានី ៖ អត់ទាន់មានផ្ទះមានអី?

ហ៊ិន ៖ គ្មានទេៗ ហើយឆ្នាំងមានតែឆ្នាំង២ទេកូនឆ្នាំងតូចៗ ចានមានតែ២ ហូបហើយអីហើយចង ដាក់អង្រែកអីហើយជាស្រេចប្រុងរត់ទៅទៀតហើយអត់មានទិសដៅទេ?

ដានី ៖ អញ្ចឹងហូបចុកអីបានម្ហូប អង្ករមកពីណា?

ហ៊ិន ៖ អង្ករគេបើកឲ្យ ម្ហូបគេបើកឲ្យដែរ ។

ដានី ៖ ហូបគ្រប់គ្រាន់ដែរ?

ហ៊ិន ៖ បាទ!មានអីហូបគ្រប់គ្រាន់ ប៉ុនម្ហូបអត់មានទេសាច់ជ្រូកសាច់គោអីត្រីស្រស់នោះ មានតែ ត្រីកាម៉ុងត្រីអីប្រហុកប៉ោតទេមានតែរបស់ក្រៀមមានមីមានអីដែរ បើកប៊ីចេង បើកស្ករ បើកខ្ទាញ់ដែរហូបគ្រប់គ្រាន់ ។

ដានី ៖ បាទ!អញ្ចឹងកន្លែងសម្រាកផ្ទះអីយើងសម្រាកនៅណា?

ហ៊ិន ៖ ដំយើងនៅបានយូរបន្តិចទៅបានយើងចាប់ផ្ដើមធ្វើរោង ។

ដានី ៖ ធ្វើរោងនៅម្ដុំណា?

ហ៊ិន ៖ ធ្វើរោងមិនទៀងទេមិនដឹងប៉ុន្មានគ្រឡប់ហើយ ទឹមធ្វើសមាហរណកម្មហើយបានម៉ោនៅហ្នឹង

ដានី ៖ អ្ហូ!សមាហរណកម្មហើយបានម៉ោធ្វើផ្ទះនៅហ្នឹង?

ហ៊ិន ៖ បាទ!ក្រោយមកទៀតធ្វើនៅឆ្នាំ២០០៣ហើយពីដើមដើរនៅណាធ្វើរោងតូចៗហ្នឹង អញ្ចឹង បានខ្ញុំរាល់ថ្ងៃចេះតែប្រាប់បងប្អូនយើងថា យើងពីមុនម៉ោ ខ្ញុំចេះតែនិយាយថាយើងត្រូវ ក្រឡេកមើលកាលទាំង៣ អតីតកាល បច្ចុប្បន្នកាល អនាគតកាល មិនអញ្ចឹង?

ដានី ៖ បាទ!

ហ៊ិន ៖ ឥឡូវយើងម៉ោពីបច្ចុប្បន្នកាល មកដល់បច្ចុប្បន្នកាលហើយ យើងត្រូវក្រឡេកមើលទៅ អនាគតកាល ដូច្នេះយើងមកដល់បច្ចុប្បន្នកាលហើយរាល់ថ្ងៃ គេពីអតីតកាលមកដល់ បច្ចុប្បន្នកាលវាខុសគ្នាយ៉ាងណា រៀបរាប់ប្រាប់ហើយឲ្យគាត់យល់ឲ្យគាត់គិតចេះពិចារណា ហើយឲ្យគាត់ចេះធ្វើការសម្រេចចិត្ត ហើយពួកខ្ញុំនៅបងប្អូនទាំងអស់ពីមុនម៉ោ មិនសូវមាន

នោះទេ យើងមានពាដំណាក់កាល ដំណាក់កាលទីមួយឆ្នាំ១៩៩៣ កាលអ៊ុន គាត់ មានបងប្អូនលួចម៉ោឆ្លងកាត់ទៅម៉ោនៅទៅមានបានទៅនេះដំណាក់កាលទី១ ដំណាក់កាលទី២ អ្ហ៊!ដំណាក់កាលទី១ឆ្នាំ១៩៩០យើងម៉ោនៅនេះអានោះមានការបែកបាក់គ្នា កាលនោះនៅជាមួយគ្នាដែលតែ ខ្លះនៅសំពៅលូន ខ្លះនៅមាំឡៃនេះណាស់ ចេះតែម៉ោរកបងរកប្អូនស្គាល់គ្នាទៅចេះតែមានទៅ ហើយពីមុនម៉ោមិនសូវមានទេ មកឆ្នាំ១៩៩៣បោះឆ្នោតអ៊ុន គាត់នេះបានមានច្រើនបន្តិច ដល់ឆ្នាំ៩៦-៩៧បានច្រើនរហូតមកដល់ឥឡូវនៅតែយើងទទួលបន្ទុកធ្ងន់ទៀត ព្រោះបងប្អូនដែលម៉ោពីក្នុងម៉ោៗចេះតែរកៗបងប្អូនទី១ទី២ទៀតចេះតែម៉ោៗបង្ករការរំខានរញ្ជើ អញ្ចឹងវាកាន់តែពិបាកថែមទៀត ។

ដានី ៖ អញ្ចឹងអ៊ំម៉ោនៅតាំងពីឆ្នាំ៨៣ដល់ពេល៨៥អ៊ំទៅនៅជំរុំ?

ហ៊ុន ៖ បាទ!

ដានី ៖ ពេលហ្នឹងយួនហើយកងទ័ពរដ្ឋកម្ពុជាគេចូលម៉ោនេះ?

ហ៊ុន ៖ បាទ!ម៉ោនៅនេះដល់ឆ្នាំ៩០បានយើងវ៉ៃយកវិញ យើងមកនៅវិញម្ដង

ដានី ៖ អញ្ចឹងអ៊ំធ្វើគ្រូបង្រៀនឆ្នាំណា?

ហ៊ុន ៖ ឆ្នាំ៨៥

ដានី ៖ អញ្ចឹង៨៥ពេលដែលយួនចូលវ៉ៃបានត្រង់នេះ យើងចូលទៅនៅដីថៃនេះអ៊ំធ្វើគ្រូ?

ហ៊ុន ៖ បាទៗ!

ដានី ៖ ធ្វើគ្រូនៅកន្លែងណា?

ហ៊ុន ៖ ធ្វើនៅនឹងដីថៃនឹងឯង ទៅនៅឯថៃបើតាមពិតយើងទៅនៅដីគេទេ ។

ដានី ៖ គេហៅអីគេហ្នឹង៨៥ហ្នឹង?

ហ៊ុន ៖ ជុំថង ស្រុកថៃគេហៅជុំថង ប៉ុនយើងឲ្យឈ្មោះថា៨៥ ព្រោះយើងទៅនៅឆ្នាំ៨៥ ។

ដានី ៖ ខេត្តអីគេហ្នឹង?

ហ៊ុន ៖ ខេត្តស្រះកែវ ។

ដានី ៖ អញ្ចឹងយើងបង្រៀនហ្នឹងយើងបង្រៀនយ៉ាងម៉េច មានប៉ុន្មានថ្នាក់ ហើយបង្រៀនកូនសិស្សយ៉ាងម៉េច?

ហ៊ុន ៖ បានត្រឹមថ្នាក់ទី៤ ព្រោះសមត្ថភាពខ្ញុំបង្រៀនបានត្រឹមតែថ្នាក់ទី៤ ។

ដានី ៖ អ៊ំកាលហ្នឹងអ៊ំបង្រៀនថ្នាក់ទី១ទី២ទី៣ទី៤ហ្នឹង មានតែមួយម្នាក់អ៊ំឬក៏មានគេទៀត?

ហ៊ុន ៖ កាលហ្នឹងចេះចាំមើល គ្រូវាមានគ្រូខ្ញុំពាងចាស់ជាងគេកាលហ្នឹង ព្រោះខ្ញុំអាយុ៤០ហើយ

ឆ្នាំ៨៥ខ្ញុំអាយុ៤០ហើយ ហើយគ្រូអស់នោះសុទ្ធតែក្មេងៗហើយខ្ញុំចាស់ជាងគេ ហើយគ្រូក្មេងៗច្រើនគេយកទៅប្រចាំការនៅតាគង់ឯនោះ នៅចៃម៉ែ នៅបាឡាំងអី ច្រើនគេយកទៅប្រចាំការនៅ ដឹកអង្ករឡូកង៍ទ័ពនៅនោះ ហើយខ្ញុំបង្រៀនចាប់ពីថ្នាក់ទី១រហូតដល់ថ្នាក់ទី៤ ។

ដានី ៖ បង្រៀនតែម្នាក់ឯង?

ហ៊ិន ៖ ម្នាក់ឯង

ដានី ៖ បង្រៀនម៉េចទៅអញ្ចឹងអ៊ីតែម្នាក់ឯងអញ្ចឹង?

ហ៊ិន ៖ ខ្ញុំមួយម៉ោងដូនថាម៉ាព្រឹកកំពុងរៀន២ថ្នាក់ ថ្នាក់ទី១ទី២ ម៉ាព្រឹកចាប់ពីម៉ោង៨ដល់ម៉ោង១០ វា២ម៉ោងអញ្ចឹង ថ្នាក់នេះមួយម៉ោងថ្នាក់មួយម៉ោងទៅណា៎ ហើយបង្រៀនពីម៉ោង១អីទៅរហូតដល់ម៉ោង៤ ថ្នាក់នោះមួយម៉ោងថ្នាក់នេះមួយម៉ោងទី៣ទី៤ទៅ ។

ដានី ៖ កូនសិស្សច្រើនទេកាលហ្នឹង?

ហ៊ិន ៖ ច្រើនបាទ!

ដានី ៖ ចុះកាលហ្នឹងខាងគេចាត់តាំងឲ្យអ៊ំធ្វើគ្រូឬយ៉ាងម៉េច?

ហ៊ិន ៖ គេចាត់តាំង ។

ដានី ៖ ពីណាគេអ្នកចាត់តាំង?

ហ៊ិន ៖ ដូចមានអ្នកដឹកនាំគេនៅកន្លែងនោះឯង ។

ដានី ៖ ពីណាគេអ្នកដឹកនាំនៅកន្លែងហ្នឹង?

ហ៊ិន ៖ កាលហ្នឹងខ្មោចយ៉ែមគេស្លាប់ហើយ គេអ្នកដឹកនាំយើងទៅជំរុំនោះណា

ដានី ៖ ឈ្មោះយ៉ែម?

ហ៊ិន ៖ ឈ្មោះយ៉ែមប៉ុនស្លាប់ហើយ ដល់ពេលក្រោយម៉ោខាងសិក្សាអប់រំហ្នឹងមានឈ្មោះ ឡុង ភេន ហ្នឹងក៏ស្លាប់ដែរ ហើយបានម៉ោបន្ទាប់ទៀតនៅភូមិដែលខ្ញុំនៅគេហៅភូមិអូរសោឡោ នោះតាហ្នឹងក៏ស្លាប់ដែរឈ្មោះតាជឿន គាត់គ្រប់គ្រងនៅហ្នឹងនោះ គាត់ឲ្យខ្ញុំធ្វើព្រោះឃើញក្មេងៗវាអត់ចេះអក្សរ ។

ដានី ៖ អ៊ំធ្វើគ្រូដងធ្វើនាយកសាលាខ្លួនឯងផង?

ហ៊ិន ៖ អត់ទេៗមានគេធ្វើនាយកសាលា នេះៗនាយកសាលាគាត់នៅរាល់ថ្ងៃហ្នឹង គាត់ចេះ ជាងខ្ញុំ ។

ដានី ៖ គាត់ឈ្មោះអី?

ហ៊ិន ៖ គាត់ឈ្មោះ គ្រឿន

ដានី ៖ គាត់ធ្វើនាយក?

ហ៊ិន ៖ ធ្វើនាយក

ដានី ៖ គ្រូមានប៉ុន្មាននាក់?

ហ៊ិន ៖ កាលនោះមានច្រើនដែរ មុននោះមានតិចទេ ប៉ុនយើងចេះតែមើលអ្នកណាវាងចេះៗរើសដាក់ៗបានច្រើនៗ

ដានី ៖ អញ្ចឹងបង្រៀនឆ្នាំ៨៥នៅជុំ ដល់ឆ្នាំ៩០យើងម៉ោនេះក៏នៅបង្រៀនដែរ?

ហ៊ិន ៖ បាទ!នៅបង្រៀនដែរៗ

ដានី ៖ ចុះសាលារៀននៅណា?

ហ៊ិន ៖ សាលារៀនមិនមែននៅនេះទេ ពីមុននៅនោះនៅខាងត្បូងនៅឃុំល្វា ប៉ុនដីដីវាទាបលិចទឹកពេកលក់អាដីនោះឯង កាលនោះគេដូរដោះគ្នា ដូចដូរគ្នាទៅឲ្យដីនោះគេយកលុយគេម៉ោយកមកទិញដីនៅទល់មកសព្វថ្ងៃហ្នឹងៗ

ដានី ៖ សាលាបឹងប៉េងហ្នឹង?

ហ៊ិន ៖ បាទ!

ដានី ៖ ចុះនៅម៉ាខ្សែគេមានសាលារបស់គេផ្សេង?

ហ៊ិន ៖ បាទ!នៅមានសាលាផ្សេងៗ

ដានី ៖ អញ្ចឹងយើងរៀនបានត្រឹមថ្នាក់ទី៤?

ហ៊ិន ៖ បាទ!ត្រឹមថ្នាក់ទី៤

ដានី ៖ ចុះម៉ោវិញត្រឹមឆ្នាំ៩០ដល់ឆ្នាំ៩០ប៉ុន្មានហ្នឹងក៏ត្រឹមថ្នាក់ទី៤ដែរ?

ហ៊ិន ៖ បាទ!បានត្រឹមថ្នាក់ទី៤ដដែរ ម៉ោនៅម៉ាខ្សែគេចេះរើសស្រាវជ្រាវរកអ្នកចេះដឹងច្រើនបានដល់ថ្នាក់ទី៧-៨-៩ៗ

ដានី ៖ ចុះឥឡូវចាប់មានវិទ្យាល័យម៉ាខ្សែចាប់ពីពេលណាទៅ?

ហ៊ិន ៖ ចាប់ឆ្នាំយើងធ្វើសមាហរណកម្ម អ៊ី៩៧នេះបានមានវិទ្យាល័យ កាលនោះអនុវិទ្យាល័យ ទេដល់ឆ្នាំ២០០២បានមានវិទ្យាល័យៗ

ដានី ៖ នៅម៉ាខ្សែមានវិទ្យាល័យទេ?

ហ៊ិន ៖ មាន ឥឡូវថាបង្កើតនៅទួលគរមួយទៀតៗ

ដានី ៖ បាទ!

ហ៊ិន ៖ បាទ!កាលហ្នឹងកូនសិស្សរៀនច្រើន ហើយរៀនកាលហ្នឹងយកចិត្តដាក់ណាស់ ហើយឥឡូវកូនសិស្សខ្ញុំបានធ្វើពេទ្យរាល់ថ្ងៃ ។

ដានី ៖ អញ្ចឹងអ៊ំបង្រៀនត្រឹមឆ្នាំ៩៣ទេ?

ហ៊ិន ៖ បាទៗ!ត្រឹម៩៣

ដានី ៖ បន្ទាប់ម៉ោបានធ្វើឃុំ?

ហ៊ិន ៖ បាទ!ធ្វើឃុំនៅឃុំបឹងប៉េង ។

ដានី ៖ កាលឆ្នាំ៩៣ហ្នឹងក្រុមប្រឹក្សាឃុំ ឬក៏មេឃុំកាលហ្នឹង?

ហ៊ិន ៖ ក្រុមប្រឹក្សាឃុំ

ដានី ៖ ៩៣ចាប់មានក្រុមប្រឹក្សាឃុំ?

ហ៊ិន ៖ អត់ទេ!វាដូចតែក្រុមប្រឹក្សាអញ្ចឹងខ្ញុំមិនមែនធ្វើមេទេ ខ្ញុំធ្វើរងគេ ខ្ញុំសមាជិកគេ គេមានប្រធាន មានអនុប្រធាន ខ្ញុំសមាជិកគេ ។

ដានី ៖ ចុះអ៊ំដូចថាយើងបែងចែកជារចនាសម្ព័ន្ធ ភូមិឃុំអី ចាប់ផ្តើមមានតាំងពីអង្កាល់មក?

ហ៊ិន ៖ បើតាមពិតមានតាំងពីយើងមកដល់យើងម៉ោនៅនេះ គេបែងចែកកងទ័ពនៅកងទ័ព ប្រជាជនគេរៀបចំភូមិឃុំអី មានអ្នកគ្រប់គ្រងក្រុម ។

ដានី ៖ បាទ!ដូចភូមិយើងមានដូចជាភូមិចំបក់ ភូមិបឹងប៉េង ភូមិសង្កែ ភូមិភ្នំរូងភូមិ ភូមិជ្រៃភូមិល្មាអីហ្នឹង អាហ្នឹងមានឈ្មោះហ្នឹងតាំងពីអង្កាល់?

ហ៊ិន ៖ តាំងពីយើងម៉ោនៅម៉ោ៩០ម៉ោនៅ ។

ដានី ៖ ឈ្មោះហ្នឹងយើងដាក់ខ្លួនឯងឬមានតាំងពីដើមម៉ោ?

ហ៊ិន ៖ អត់ទេ!យើងដាក់ខ្លួនយើង យើងម៉ោរៀបចំ ។

ដានី ៖ ពីណាគេអ្នករៀបចំ?

ហ៊ិន ៖ ចុះធម្មតាតែយើងនៅគឺមានអ្នកដឹកនាំហើយ មានអ្នកដឹកនាំស្រុកមានអ្នកដឹកនាំខេត្ត ។

ដានី ៖ ពីណាគេអ្នកដឹកនាំ?

ហ៊ិន ៖ ចាំមើលខាងនេះ ឈឹម មន្នី គាត់ដឹកនាំខាងរដ្ឋបាល ខាងប្រជាជនព្រោះពីដើមគាត់កងទ័ពដែល ប៉ុនដល់គាត់អង្កត់ជើងទៅគេឲ្យគាត់មកគ្រប់គ្រងរដ្ឋបាល ។

ដានី ៖ អ៊ូ!មាន ឈឹម មន្នី ពីណាទៀត?

ហ៊ិន ៖ ឈឹម មន្នី ភី ភន ដូចមានតែ២ហ្នឹងឯងមនុស្សសំខាន់ ហើយគេរៀបចំភូមិឃុំអីទៅ ។

ដានី ៖ ចាប់ពីឆ្នាំ៩០ម៉ោ?

ហ៊ិន ៖ បាទ!៩០ម៉ោ

ដានី ៖ មានភូមិ មានឃុំ មានមេភូមិ មានមេឃុំអញ្ចឹងទៅ?

ហ៊ិន ៖ បាទ!ហ្នឹងហើយ

ដានី ៖ ហើយកាលពីដំបូងកន្លែងហ្នឹងសុទ្ធតែព្រៃ?

ហ៊ិន ៖ បាទ!សុទ្ធតែព្រៃ៧/៩សុទ្ធតែព្រៃ ។

ដានី ៖ ចុះវាលហ្នឹងយ៉ាងម៉េច ចាប់ផ្ដើមវាលតាំងពីអន្កាល់?

ហ៊ិន ៖ ចាប់ផ្ដើមវាលចាំមើលតាំងពី៨៥ ៨៥ខ្ញុំម៉ោនៅនេះយើងចាប់ផ្ដើមកាប់ឆ្ការព្រៃឲ្យវាវាល ព្រោះមានព្រៃវាគ្រុន ធ្វើម៉េចឲ្យវាស្រលះឲ្យមានខ្យល់ចេញចូល ដើម្បីកាត់បន្ថយអានុភាពគ្រុនចាញ់ ហើយយើងចេះតែកាប់ៗវាទៅ ហើយឃើញថៃយើងចេះដាំពោត ដាំសណ្ដែកទៅដើម្បីយកទៅលក់ឲ្យថៃ រួមផ្សំរបបដែលគេចែកឲ្យផងទៅ យើងសន្សំផ្គត់ផ្គង់ ដូចថាយើងចង់ហូបអី ហើយយើងមានចិញ្ចឹមជ្រូកចិញ្ចឹមមាន់ ដូចខ្ញុំមិនបានចិញ្ចឹមប្អូនឯងចិញ្ចឹមយើងទិញផ្សារទៅ ។

ដានី ៖ បាទ!យើងចេះតែកាប់ព្រៃ

ហ៊ិន ៖ កាប់ឈើ អាលឈើយកទៅលក់ឲ្យថៃ គេហាមទេ តែយើងចេះតែលួចទៅ

ដានី ៖ បាទ!

ហ៊ិន ៖ ឈើធំៗសុទ្ធតែប៉េង មើលខ្ញុំនៅសល់តែប៉ុណ្ណឹងមើលលក់ឲ្យថៃអស់ ហើយអត់ទេអាណារយើងអាលនឹងអាណារដៃ ។

ដានី ៖ ចុះគេគ្រប់គ្នាអាលអាណារដៃគ្រប់គ្នាគេអាលតាមសមត្ថភាពរបស់គេអញ្ចឹង?

ហ៊ិន ៖ បាទ!អ៊ើមានគេទិញអាណារចូលគ្នាដែរ ដូចជាខ្ញុំនឹងប្អូនឯងនៅជិតគ្នា ចូលលុយគ្នាទិញចូលគ្នាទៅយើងអាលចូលគ្នាទៅ ពេលថៃម៉ោមើលត្រូវការទិញលីយកទៅលក់ឲ្យវាទៅសន្សំៗ លុយហើយម៉ោចាប់វាលខ្លាំងនៅឆ្នាំ១៩៩៣កាន់តែវាលខ្លាំង រហូតមកដល់ឥឡូវនេះកាន់តែរុករានហើយបានវាលអស់អញ្ចឹង ។

ដានី ៖ អញ្ចឹងចាប់ពីសមាហរណកម្មនៅខែ៨ឆ្នាំ១៩៩៦ អញ្ចឹងយើងកាលហ្នឹងចាប់ផ្ដើមដូចថាដីមានផ្ទះសម្បែង មានរបបគេចែក?

ហ៊ិន ៖ បាទៗចែក ដីនេះគេចែក តែតាមពិតផ្លូវនេះផ្លូវរដ្ឋកម្ពុជាទេ កងទ័ពកម្ពុជាទេគេធ្វើទៅដល់យើងម៉ោ ម៉ោនៅផ្លូវគេ ដល់ហើយគេចែកឲ្យម៉ាគ្រួសារ៥០ម៉ែត្រហិតា ហើយផ្លូវកាលនោះគ្មានផ្លូវនេះអីកាលនោះផ្លូវនោះទេ ។

ដានី ៖ ចុះពេលដែលយើងម៉ោវិញឆ្នាំ៩៣ ដូចថាពេលដែលកងទ័ពវៀតណាម កងទ័ពរដ្ឋកម្ពុជាដកចេញទៅសំបូរមីនទេ?

ហ៊ិន ៖ សំបូរ

ដានី ៖ សំបូរយើងធ្វើម៉េចទៅ យើងដោះខ្លួនឯងឬមានកងទ័ពគេមកដោះឲ្យ?

ហ៊ិន ៖ យើងដោះខ្លួនឯង ភាគច្រើនដោះខ្លួនឯង ។

ដានី ៖ ចុះអ៊ំដោះខ្លួនឯងដែរឬអត់?

ហ៊ិន ៖ ដោះខ្លួនឯងដែរ ហើយដឹងត្រឹមថាខ្ញុំម៉ោដល់មានលុយទិញគោបានមួយនឹម មានលុយ ១៣០០០ទិញគោបានមួយនឹមគោទឹម ទិញម៉ោខ្ញុំយកឲ្យវាភាវមីន ។

ដានី ៖ ឲ្យវាភាវម៉េចទៅ?

ហ៊ិន ៖ ចុះយើងចងដាក់ខ្សែវាមិនឲ្យវាដើរទៅ វាដើរទៅយើងទាញមកវិញហើយយើងដេញទៅ ទៀតអត់មានមីនខ្ញុំចេះតែដេញទៅទៀត ។

ដានី ៖ ចុះគោអត់មានត្រូវអី?

ហ៊ិន ៖ អត់ត្រូវអីទេ បំបោលវាទៅវាជាន់ជ្រុះរោមមុតជើង មុតជើងបានដឹងថាអ៊ូដល់ហើយឈប់ ទៅព្រោះខ្ញុំខាងនេះទៅ ខាងនេះទៅមិនមានមីនទេ ទៅតាមមាត់អូរបានមានមីនព្រោះរដ្ឋកម្ពុជាដាក់ខ្លាំងណាស់ ដាក់សម្រូងដែកអា ឥឡូវអស់ទងមពួកស៊ីម៉ាក់គេមកភាវអស់ កាលមុនផ្ទុះច្រើនណាស់ ងាប់ ស្លាប់ របួស ពិការ ។

ដានី ៖ ចុះដីចំការយើងចាប់ខ្លួនឯងឬគេចែកឲ្យ?

ហ៊ិន ៖ ដីគេចែកតែដីភូមិទេ ដីចំការយើងចាប់ខ្លួនយើង ទៅចាប់ទៅតាមឆ្ងាយៗទៅតាមលទ្ធភាពយើងទៅ បើខ្ញុំអត់ទេអត់បានចាប់ទេរវល់តែធ្វើការងាររបស់ខ្ញុំ ។

ដានី ៖ អត់មានដីទេអញ្ចឹង?

ហ៊ិន ៖ អត់មានទេ មានតិចណាស់មានដីតិចអាគេចែកឲ្យ ហើយទៅចាប់បាន៥ហត្ថ ប៉ុន្ដឹកូនច្រើនពេកចែកកូនអស់ហើយ ។

ដានី ៖ ចុះអ៊ំមាននៅធ្វើចំការដែរ?

ហ៊ិន ៖ ធ្វើខ្ញុំនៅធ្វើបន្តិចប្រហែលជា១ហត្ថា

ដានី ៖ ចុះអ៊ំឆ្នាំណាទៅលេងស្រុកវិញ?

ហ៊ិន ៖ ទៅរាល់ឆ្នាំខ្ញុំ មិនដែលខានទេ ។

ដានី ៖ ខ្ញុំចង់ដឹងពេលដែលយើងបែកម៉ោ?

ហ៊ិន ៖ ឆ្នាំ៩៧

ដានី ៖ ឆ្នាំ៩៧ទៅលើកទី១ ?

ហ៊ិន ៖ បាទ!

ដានី ៖ មានបែកទេកាលយើងទៅលេងកសលឆ្នាំ៩៧ ?

ហ៊ិន ៖ ទៅខាងស្រុកខ្ញុំមានអីរត់បោលស្រុកដូចគ្នា ខ្ញុំទៅគេក៏ទឹមម៉ោដែរ ចុះកាលគេហៅតំបន់កំពុងប្រទង់ប្រទាញ ទៅកន្លែងខ្មែរក្រហមចូល រដ្ឋកម្ពុជាចេញ រដ្ឋកម្ពុជាចូល ខ្មែរក្រហមចេញ ដូចច្នេះបើទុកប្រជាជននៅនោះវាមិនគ្រោះថ្នាក់ ដ៏ហើយគេជម្លៀសឲ្យទៅនៅជិតកំពង់ធំនៅទីរួមខេត្ត ដល់យើងធ្វើសមាហរណកម្មនេះត្រូវគ្នាទៅបានវាកាត់បន្ថយខ្មែរក្រហម បានពួកហ្នឹងមកនៅក្នុងភូមិវិញ ទឹមមកនៅវិញដែរ តំណាលតែគ្នា ។

ដានី ៖ បាទ!ប៉ុន្តែនៅបែកគ្នាយូរអញ្ចឹងជួបគ្នាវិញស្គាល់គ្នាទេ?

ហ៊ិន ៖ ស្គាល់តែអ្នកពេញវ័យដូចគ្នា អ្នកដែលកើតក្រោយអត់ស្គាល់គ្នាទេ ហើយខ្ញុំស្គាល់តែបងខ្ញុំប្អូនៗខ្ញុំដែលពេញវ័យដូចគ្នា ដល់អាប្អូនពីរនាក់ក្រោយអត់ស្គាល់វារលីង វានៅតូចនោះដល់ខ្ញុំទៅចង់ចាស់ប៉ុនគ្នានោះ ។

ដានី ៖ ចុះញាតិមិត្តអីអ្នកជិតខាង?

ហ៊ិន ៖ ញាតិមិត្តអីនៅចាស់ៗនៅស្គាល់គ្នា ។

ដានី ៖ អញ្ចឹងឆ្នាំក្រោយៗម៉ោអំទៅរាល់ឆ្នាំ?

ហ៊ិន ៖ បាទ!ខ្ញុំទៅរាល់ឆ្នាំ ប៉ុនកាលខ្ញុំនៅគ្រូបង្រៀនខ្ញុំខស្សព្រាហ៍ទៅអន្លង់វែង ខ្ញុំខស្សព្រាហ៍ទៅនោះពេលកូនអ៊ំ អៀង សារី បបួលទៅ ។

ដានី ៖ កូនអ៊ំសារីពីណាគេ?

ហ៊ិន ៖ អៀង វុធ

ដានី ៖ ស្គាល់គាត់?

ហ៊ិន ៖ ស្គាល់ពីមុន

ដានី ៖ ស្និតស្នាលជាមួយគាត់ទេ?

ហ៊ិន ៖ ស្និតស្នាលកាលមុន តែឥឡូវលែងស្គាល់ឯងបាត់ហើយតាមមើល មិនដែលជួបគ្នាទេតាំងពី៩៣ម៉ោបែកគ្នារហូត អើស៍ត្រឹមសមាហរណកម្មហើយគាត់ទៅនៅប៉ៃលិនទៅបែកគ្នា រហូត ។

ដានី ៖ បែកគ្នារហូតទៅ?

ហ៊ិន ៖ បាទ!

ដានី ៖ កាលហ្នឹងអ្នកណាដែលជាមិត្តភក្រអ៊ំ?

ហ៊ិន ៖ មិនទេ!ចុះធ្វើការគាត់នៅក្រប់គ្រងអាកន្វែង យើងមិនទៅបើកអង្គរបើកអីមិនមេនាំទៅ មិនមេឃុំនាំទៅ ជំទប់ទី១ ជំទប់ទី២ រៀបចំហើយស្រេច ទៅមិននាំប្រជាជនទៅបើកអង្ករហើយគាត់ក៏បើកអង្ករឲ្យយើង ។

ដានី ៖ អ៊ូគាត់ជាអ្នកទួលខុសត្រូវនៅកន្លែងភស្តុសភាមាំ ស្រុកមាំខ្សែឃ្នឹង

ហ៊ិន ៖ បាទ!មាំមាំខ្សែហ្នឹង

ដានី ៖ កងទ័ពអីក៏ទៅបើកកន្លែងគាត់ដែរ?

ហ៊ិន ៖ បើកកន្លែងគាត់ដែរ ប្រជាជនក៏ទៅកន្លែងគាត់ដែរ ។

ដានី ៖ អៀង វុធ

ហ៊ិន ៖ អៀង វុធហ្នឹង ។

ដានី ៖ ហើយចុះអ៊ំ អៀង សារីគាត់ទៅនៅណា?

ហ៊ិន ៖ អ៊ំ អៀង សារីគាត់នៅនេះដែរ ប៉ុន្តែកាលនោះគាត់ម៉ោនៅនេះដែរ តែគាត់មិនសូវនេះទេគាត់នៅណានោះ ។

ដានី ៖ ចុះ អៀង វុធ នៅហ្នឹងដាប់?

ហ៊ិន ៖ បើអៀង វុធ កូនគាត់នៅនេះដាប់ ។

ដានី ៖ អញ្ចឹងគាត់ខស្សាហ៍ទៅអន្លង់វែងដែរ?

ហ៊ិន ៖ ខស្សាហ៍ទៅ ខ្ញុំធ្លាប់ទៅជាមួយគាត់បានមួយដង ។

ដានី ៖ ជិះអីទៅ?

ហ៊ិន ៖ ជិះឡានៗថៃ ដល់ហើយក្រោយម៉ោខ្ញុំនៅធ្វើគ្រូបង្រៀននេះ ក៏មានគ្នាឯងធ្លាប់ស្គាល់គ្នានៅអាងប៉ៃយើងគេឲ្យទៅលេង ហើយកងពល៥១៩យើងពីដើមនោះគេចេះតែផ្ដាំឲ្យយើងទៅលេងដឹទៅជួបជាមួយអ្នកអន្លង់វែង ខ្ញុំខស្សាហ៍ផ្ញើរសំបុត្រផ្ញើររូបថតតាមពួកហ្នឹងទៅអ្នកផ្ទះនៅកំពង់ធំ ។

ដានី ៖ ហើយចុះខាងនោះមានផ្ញើរសំបុត្រអីមកអ៊ំវិញដែរឬអត់?

ហ៊ិន ៖ អត់ទេ! អត់ដែលបានទេ ។

ដានី ៖ ចុះអ៊ំអត់ចង់ទៅនៅស្រុកវិញទេ?

ហ៊ិន ៖ អត់ទេ! ព្រោះចេះស្រុកខ្ញុំវានៅជនបទឆ្ងាយ ការផ្ដល់សេវាជូនប្រជាជនមិនបានដូចយើងនៅនេះ ។

ដានី ៖ ចុះដូចថាញាតិមិត្ត មិត្តភក្ដិអ្នកជិតខាងអីគេនៅរាប់អានអ៊ំដូចពីអ៊ំនៅស្រុកហ្នឹងដែរឬអត់ទេ ដោយសារយើងបែកគ្នាយូរហើយ?

ហ៊ិន ៖ រាប់អាន អ្ហ៊ូបើថាខ្ញុំទៅវិញអត់បានដើរទៅណាទេ មួយម៉ោមួយចេញមួយចូល១មួយថ្ងៃៗ ជជែកគ្នាឡើងបែកពពុះមាត់ ។

ដានី ៖ ចុះអ្នកប្រជាជនគេស្អប់អ៊ំទេ ដូចថាអ៊ំធ្លាប់ធ្វើជាកម្មាភិបាល?

ហ៊ិន ៖ អត់ទេៗស្អប់ទេ ព្រោះខ្ញុំមិនដែលបានធ្វើអីឲ្យគាត់គាស់គើងទាស់ចិត្តខុសឆ្គងជាមួយគាត់ផង ព្រោះខ្ញុំទៅឆ្ងាយៗពីគាត់បាត់ទៅ ។

ដានី ៖ បាទ!ប៉ុនអ៊ំមានប្រសាសន៍មុនថាអ៊ំអត់ហ៊ានចូលទៅស្រុក ដោយសារខ្លាចប្រជាជន សម្លាប់?

ហ៊ិន ៖ ខ្លាចដែរ បើពាក្យសាមញ្ញវិញគេថាសម្ងំពីស ព្រោះយើងនៅក្នុងបក្សហ្នឹងដែរ ទោះបី ម៉េចៗយើងចេះតែខ្លាចទៅ ។

ដានី ៖ ប៉ុន្តែអ៊ំទៅហ្នឹងអត់មានអ្នកណាស្អប់អីទេ?

ហ៊ិន ៖ អត់ទេ មានអី ស្អប់ឯណាបើមិនហ៊ានទេ ព្រោះក្មួយៗអីកាលខ្ញុំទៅ៩៧ ក្មួយៗគេសុទ្ធតែ ធ្វើកងទ័ព ឈ្លបភូមិ ឈ្លបឃុំអី ។

ដានី ៖ ទោះគេស្អប់ម៉េចក៏គេមិនហ៊ានទេ?

ហ៊ិន ៖ បាទ!មិនហ៊ានទេ

ដានី ៖ ប៉ុនអ៊ំមើលទៅគេ មើលទៅឃើញគេស្អប់អ៊ំដែរទេ?

ហ៊ិន ៖ មិនទេមិនស្អប់ទេ

ដានី ៖ ដូចថាគ្រាន់តែអ្នកភូមិអីយើងមើលទឹកមុខអី?

ហ៊ិន ៖ អត់ទេៗ!គ្រាន់តែខ្ញុំទៅដូចខ្ញុំថាអញ្ចឹងមួយចេញមួយចូល

ដានី ៖ ចុះបើបងប្អូនអ៊ំវិញ ដូចថាក្មួយ ដូចប្អូន ដូចជាបងអីយ៉ាងម៉េចដែរដូចថាយើងបែកគ្នាយូរ ដូចថាមនោសញ្ចេតនានៅតែជិតស្និតដូចមុនទេ?

ហ៊ិន ៖ ដូចតែពីមុនដែរ ។

ដានី ៖ គាត់ធ្លាប់មកលេងអ៊ំនៅនេះទេ?

ហ៊ិន ៖ ម៉ោបងក៏ម៉ោ ប្អូនក៏ម៉ោ បើថាខែភ្ជុំឆ្នាំនេះបងថាcallឲ្យទៅ ព្រោះយើងចាស់ៗរៀងៗខ្លួន ហើយ ទៅជួបជុំគ្នាម្ដង ។

ដានី ៖ ដូចអ៊ំៗអត់ចង់ទៅនៅនោះទេ អ៊ំចង់នៅនេះជាង?

ហ៊ិន ៖ បាទ!

ដានី ៖ ដោយសារអ៊ំគិតថានៅនេះស្រួលជាងនៅនេះ?

ហ៊ិន ៖ បាទស្រួលជាងនៅនេះ ប៉ុនគេនៅនោះគេម៉ោនេះវិញ គេថានៅនេះគេមិនចេះនៅ វិញ ដូចបងម៉ោគាត់ថាមិនចេះនៅទេ កាលម៉ោការកូនខ្ញុំមីបង ។

ដានី ៖ បើអ៊ំក៏មិនចេះនៅនោះដែរ?

ហ៊ិន ៖ បាទ!ព្រោះធ្លាប់នៅនេះហើយ នៅនោះវាថាការផ្ដល់សេវាជូនប្រជារាស្ត្រវាដាច់ស្រយាល នៅនេះទោះបីយ៉ាងណាក៏ដោយការផ្លាស់ប្ដូរវាទៅតាមកាលៈទេសៈ ។

ដានី ៖ ចុះដូចថារបៀបការរាប់អានយើងនៅនេះម៉េចដែរ ដូចថាការរាប់អានជាមួយមិត្តភក្រ្ត អ្នកជិតខាងមានការរាប់អានម៉េចដែរ?

ហ៊ិន ៖ ចុះមានណានេះអ្នកតាកែវៗ ៗ អ្នកតាកែវច្រើននេះ ម៉េញអ្នកម៉ោមិញនេះអ្នកកំពង់ចាម ប៉ុនយើងចេះតែចងក្រងគ្នាទៅ ម្យ៉ាងដូចខ្ញុំនេះវាមានបទពិសោធន៍ក្នុងការគ្រប់គ្រង ហើយក៏យើងបានសិក្សារៀនសូត្រច្រើនទៅយើងចេះតែរាប់អានគ្នាទៅ ដូចច្នេះយើងចេះតែជួយគ្នាជួយទុក្ខធុរៈគ្នាទៅវិញទៅមកយើងចេះតែជួយគ្នាទៅដូចបងប្អូនបង្កើតអញ្ចឹង ។

ដានី ៖ ជួយគ្នាទៅវិញទៅម៉ោ?

ហ៊ិន ៖ បាទ!ជួយគ្នាទៅវិញទៅម៉ោ

ដានី ៖ អ៊ំថាម៉េចទៅដូចមិញអ៊ំថាកាលពីមុនសុទ្ធតែព្រៃ តទៅថ្ងៃអនាគតគេអភិវឌ្ឍន៍ទៅមុខទៀត អ៊ំគិតធ្វើម៉េចទៀតទៅថ្ងៃអនាគត?

ហ៊ិន ៖ អញ្ចឹងបានខ្ញុំនិយាយថាបើដល់អនាគតកាល យើងគិតមើលមកដល់បច្ចុប្បន្នកាលយើងមើលអនាគតកាល ចង់និយាយថាបើយើងដើរមកដល់នេះយើងក្រលេកមើលទៅក្រោយ ដូច្នេះពីនោះមកដល់នេះវាមានបញ្ហាអីខ្លះ វាយ៉ាងម៉េចខ្លះនៅក្នុងជីវិតរបស់យើង តាំងពីតូចមកដល់ប៉ុននេះវាយ៉ាងម៉េចខ្លះហើយដល់នេះដល់ម៉ោបច្ចុប្បន្នកាល ដូច្នេះយើងចង់និយាយថា នៅអនាគតកាលយើងមិនចង់ឲ្យជាតិយើងខ្លួនរបស់យើងនឹងវិញទៅរកអតីត កាល ។

ដានី ៖ អ៊ំសង្ឃឹមថានៅម៉ាឡៃយើងថ្ងៃអនាគតទៅយ៉ាងម៉េចទៅ?

ហ៊ិន ៖ ខ្ញុំសង្ឃឹមថានឹងមានការអភិវឌ្ឍន៍ នឹងមានការរីកចំរើន ។

ដានី ៖ ចុះមួយទៀតខ្ញុំចង់ដឹងថា ក្រោយពីសមាហរណកម្មទៅយើងមានចំនុចវិជ្ជមាន អវិជ្ជមានដូចម្ដេចខ្លះ?

ហ៊ុន ៖ អញ្ចឹងបានខ្ញុំថាខ្លះក៏បានសិក្សារៀនសូត្រគេចេះតែយល់បាន តែខ្លះគ្នាមិនបានសិក្សារៀនសូត្រក៏យើងចេះតែនិយាយប្រាប់ខ្លះៗឲ្យដឹង ព្រោះកត្តានៅក្នុងជាតិយើងវាមាន២ដែលសំខាន់ជាគន្លឹះ មានកត្តា ប្រជាជន នឹងកត្តាដឹកនាំ យើងចង់មានអ្នកដឹកនាំជាកត្តាគន្លឹះ១របស់ជាតិ ប្រជាជនក៏ជាគន្លឹះមួយសំរាប់ជាតិ ចង់ឲ្យធ្វើយ៉ាងម៉េចយើងនឹងដឹកនាំកុំឲ្យវាបែកគ្នា ចង់ឲ្យអ្នកដឹកនាំយល់ដឹងពីអីដែលវាអន្តរាយ វាហិនហោច វាបាត់បង់ អាអ៊ីវារីកចំរើន អាអ៊ីវាវិជ្ជមាន អាអ៊ីវាអវិជ្ជមាន ។

ដានី ៖ ប៉ុន្តែមួយទៀតខ្ញុំចង់ដឹងថានៅម៉ាខ្សែយើង កាលពីមិនទាន់សមាហរណកម្មមានចំណុចល្អមានចំណុចអាក្រក់យ៉ាងម៉េចខ្លះ ហើយដល់ពេលសមាហរណកម្មហើយវាមានចំណុចល្អវាមានចំណុចអាក្រក់យ៉ាងម៉េចខ្លះ?

ហ៊ុន ៖ ឥឡូវខ្ញុំចង់និយាយឲ្យខ្លីពីមុនម៉ោព្នុសូរតែកាំភ្លើង ឥឡូវអត់ដែលព្នុសូរកាំភ្លើងហើយក៏មិនមានកាំភ្លើងទៀត អានេះហើយជាចំណុចវិជ្ជមានព្រោះវាមានកាំភ្លើងព្នុសូរបាញ់គ្នា កាប់សម្លាប់គ្នា កុំគួនគ្នា ឥឡូវនេះវាអត់ទាំងព្នុសូរកាំភ្លើងថែមទាំងអត់មានកាំភ្លើងទៀតអានេះហើយដែលជាតំរូវការជាសំណូមពរដ៏ទទូចបំផុតរបស់ប្រជាជនយើង ព្រោះសន្តិភាពមិនមានតែខ្មែរទេចង់បាន ពិភពលោកចង់បានសន្តិភាព ដូច្នេះហើយដូចខ្ញុំថាកត្តាជាគន្លឹះដ៏សំខាន់មានកត្តា២ មានកត្តាប្រជាជននឹងកត្តាដឹកនាំ នេះហើយជាកត្តាសម្រាប់ជាតិ បើដឹកនាំប្រកបដោយគតិបណ្ឌិតវៃឈ្លៀស ខ្ញុំសុំអធ្យាស្រ័យចុះ ដូចជាសម្តេចសេនាតេជោ ហ៊ុន សែន ជាប្រមុខនៃប្រជាជនយើង ជាជាតិយើង លោកមានគតិវៃឈ្លៀស ហើយជាគន្លឹះសម្រាប់ឲ្យយើងធ្វើការអភិវឌ្ឍន៍ទៅមុខជាលំដាប់នេះទីមួយ ទីពីរទៀត ៣ឆ្នាំ៨ខែ ២០ថ្ងៃជាតិយើងធ្លាក់ដល់កំរិតសូន្យលើគ្រប់វិស័យមិនអញ្ចឹង?

ដានី ៖ បាទ!

ហ៊ុន ៖ ខ្ញុំ សារក្រោយបន្តិចចុះ កាលនៅគ្រូបង្រៀនមានតែខ្ញុំចាស់ជាងគេ ដូចដើមអត្ថបទ បង្រៀនរៀបចំអក្សរកខគឃង អក្សរ៣៣តួមានប៉ុន្មាន អក្សរជ្រុង់គេគូសបន្ទាត់របៀបម៉េចអីម៉េចបង្ហាត់ក្មេងហើយធ្វើសរសេរនឹងដៃនេះ សរសេរនឹងដៃហើយមិនដាក់កាកីឲ្យសរសេរ ដាក់ម៉ាសន្លឹកទៅសរសេរបានពីរបីសន្លឹកទៅ ហើយចែកឲ្យគ្រូៗបង្រៀនទៅ ដល់ឆ្នាំ១៩៨៧ មានឈ្មោះតាយនមួយគាត់ជាសមាជិកខេត្តសៀមរាប ហើយតាខនមួយគាត់ជាសមាជិកទទួលខាងសេដ្ឋកិច្ច កសិកម្មខេត្តសៀមរាប គាត់ម៉ោ មិនរត់ទេតាមពិតខ្មែរក្រហមចាប់បាន ចាប់បានគាត់សារភាព គាត់ថាសារភាពម៉ោបានតាម៉ុកនៅអន្លង់វែងនេះ

បងឡុង ដេងនេះគាត់ប្រាប់ខ្ញុំៗថាគេមានបញ្ញាជនពីរនាក់គេមិនចេះប្រើទេ បងឯងទៅយក បានទេៗទៅយកមកឲ្យខ្ញុំ អើមិនឯងចេះប្រើអើយកម៉ោបានតែចេះខ្ញុំប្រើស្រួលណាស់ ដល់ហើយមែនដូចថា ដល់ហើយគាត់ទៅតាយ៉ៃមដូចខ្ញុំថា បានតាយ៉ៃមគាត់ទៅទាក់ទងយក មកបានមែន យកម៉ោមែនអីគេថាយកប្រើធ្វើម៉េច ចាំមើលខ្ញុំប្រើឲ្យមើល ឥឡូវឲ្យគាត់ សរសេរអត្ថបទ បង្រៀនអីចេះៗ តែងសេចក្ដី ព្រោះយើងអ្នកបង្រៀនមានពេលពីណា ទៅតែងដងទៅបង្រៀនដងហត់ណាស់ បានគាត់ម៉ោឲ្យគាត់តែងឲ្យស្រួលខ្ញុំបានអត្ថបទរៀប តាំងពីគណិតវិទ្យា ភូមិវិទ្យាអីហូរហែរម៉ោដែលគាត់ចង់ចាំបានច្រើន រហូតដល់ឆ្នាំ១៩៩០ នេះបាន អើស់៨៩នេះបានខាងដឹកនាំកម្ពុជាប្រជាធិបតេយ្យយើងនេះបានធ្លាក់សៀវភៅ គេបោះពុម្ពសៀវភៅឲ្យអាណិតវិទ្យា ភូមិវិទ្យាអីបានម៉ោបានត្រឹមថ្នាក់ទី៤ទេ ប៉ុនសរសេរ ដៃដែរ ប៉ុនគេរៀនចងក្រងជាសៀវភៅ ។

ដានី ៖ បាទ!ចុះអ៊ំមួយទៀតបច្ចុប្បន្ននេះវាមានតុលាការដើម្បីកាត់ទោស ជំនុំជំរះមេដឹកនាំខ្មែរ ក្រហម តុលាការដែលមានជួយខបត្ថមពីអង្គការសហប្រជាជាតិដែលគេដំណើរការរាល់ថ្ងៃ នេះអ៊ំមានដែលតាមដាន មានដែលដឹងពីតុលាការហ្នឹងដែរឬអត់?

ហ៊ុន ៖ ដឹងដែរ

ដានី ៖ អ៊ំយល់ឃើញម៉េចដែរតុលាការហ្នឹង?

ហ៊ុន ៖ អ៊ើ!តុលាការហ្នឹងវា ព្រោះខ្ញុំខស្សហ៍មើលការស្វែងរកការពិត

ដានី ៖ បាទៗ!

ហ៊ុន ៖ បានខ្ញុំមើលទៅបានខ្ញុំភ្ញាក់ខ្លួនថាអូ មានការកាប់សម្លាប់គ្នាមែន ព្រោះការធ្វើតុលាការកាត់ ទោសនេះព្រោះដើម្បីផ្សះផ្សា គោលបំណងការផ្សះផ្សា ចង់និយាយថាខ្ញុំបាត់បង់សមាជិក ការបាត់បង់ដោយសារគេកាប់សម្លាប់ ជនដៃដល់អ្នកកាប់សម្លាប់អ្នកណាគឺអ្នកដឹកនាំ បាន ន័យថាគេកាត់ទោសនេះផ្ដល់យុត្តិធម៌ក៏ថាបានផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះហ្នឹងទី១ ទី២គឺ ដើម្បីឲ្យអ្នកដែលនៅក្នុងរបប គេហៅថារបបឃោរឃៅចុះមិនចឹង!

ដានី ៖ បាទ!

ហ៊ុន ៖ របបប្រល័យពូជសាសន៍ របបព្រៃផ្សៃចុះ ដែលរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃបាន ហើយរស់នៅជាមួយគ្នាបានគឺទាល់តែមានការធ្វើតុលាការកាត់ទោសទើបវាអស់ចិត្តខ្ញុំគាំទ្រ

ដានី ៖ ចុះអ៊ំយល់ថាត្រឹមត្រូវដែរទេ?

ហ៊ិន ៖ បាទ!ខ្ញុំគិតថាអាអ៊ីដែលការរៀបចំឡើង កំប៉ុន្តែកុំឲ្យតែវាហួសព្រំដែននិយាយពីសិទ្ធិ ចង់និយាយពីសិទ្ធិវាសិទ្ធិរបស់ខ្ញុំវាត្រឹមដោគវាសនាទៅទល់នឹងសិទ្ធិប្អូនឯង ចង់និយាយថា សិទ្ធិខ្ញុំទៅទល់នឹងសិទ្ធិប្អូនឯង សិទ្ធិខ្ញុំទៅទល់នឹងច្បាប់ កុំឲ្យវាធ្វើអីទៅហួសពីច្បាប់ ចង់និយាយថាឥឡូវតុលាការគេកាត់ទោសតែមេដឹកនាំធំៗប៉ុន្មានរូបទេ ដែលសល់ពីអ្នកស្លាប់ទៅ មានតា នួន ជា តាខៀវ សំផន អៀង សារី តាឌុចទៅហើយ អៀង ធីរិទ្ធទៅ ។

ដានី ៖ បាទ!

ហ៊ិន ៖ អាហ្នឹងវាត្រឹមត្រូវហើយកុំឲ្យតែបានប៉ុណ្ណឹងហើយចង់បានលើសហ្នឹងទៀត អាហ្នឹងដូចអត់កើតអាហ្នឹងវាដូចទៅជាចូលក្នុងលក្ខណៈ៣ឆ្នាំ៨ខែ ចូលអាហ្នឹងទៀតហើយ ដូចខ្ញុំភ័យហើយតែចាប់មេខ្ញុំទៅខ្ញុំនៅជាមួយគាត់ខ្ញុំភ័យហើយខ្លាចគាត់ឆ្លើយដាក់អានេះទី១ ទី២ ទៀតសន្និសញ្ញាយើងនិយាយពីការគោរពសិទ្ធិមនុស្សកម្ពុជាបានចុះហត្ថលេខាហ្នឹង ថាម៉េចគេហៅថាសិទ្ធិមនុស្សមិនចឹង!

ដានី ៖ បាទ!

ហ៊ិន ៖ កុំឲ្យតែសម្លាប់បានហើយ ទោសខក្រិដ្ឋដាក់គុកមួយជីវិត

ដានី ៖ បាទ!អ៊ឹអញ្ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀតហើយ អ៊ំមានអីចង់បន្ថែមនូវអាអ៊ីដែលពួកខ្ញុំអត់បានសួរអ៊ំ?

ហ៊ិន ៖ ខ្ញុំមិនអីទេ ព្រោះខ្ញុំចង់តែសារឡើងវិញបន្តិច ការអភិវឌ្ឍន៍គឺអភិវឌ្ឍន៍ខាងធនធានមនុស្សសំខាន់មិនចឹង!

ដានី ៖ បាទ!

ហ៊ិន ៖ ម៉េចបានថាការអភិវឌ្ឍន៍ធនធានមនុស្សសំខាន់ ដូចខ្ញុំរាល់ថ្ងៃចាញ់កូនទេ ចាញ់ក្មេងៗជំនាន់ក្រោយទេ ដូចថាអ្នកដឹកនាំដែលមានគតិបណ្ឌិត ដូចខ្ញុំរាល់ថ្ងៃសុំអនុវិទ្យាល័យបានអនុវិទ្យាល័យ ហើយខ្ញុំចង់សំណូមពរដល់គ្រប់ស្ថាប័នអង្គការជាតិ អន្តរជាតិធ្វើម៉េចផ្តល់សេវានឹងគំរូវការជូនដល់ប្រជាពលរដ្ឋដែលនៅជនបទដាច់ស្រយាល ឲ្យសមស្របនឹងពាក្យស្លោកមួយមិនដឹងពីណាអ្នកថាទេ ប៉ុនពាក្យស្លោកនេះវាល្អខ្ញុំចេះតែយកមកប្រើទៅថា( "អភិវឌ្ឍន៍ជនបទហ៊ុមព័ទ្ធទីក្រុង") ។

ដានី ៖ ពាក្យស្លោកនេះពូតាំងពីអង្កាល់មក?

ហ៊ិន ៖ តាំងពីខ្មោចតាយ៉ែមនៅ តាំងពីសម័យ៨៥ ខ្មោចតាយ៉ែមគាត់នៅគាត់តែងតែនិយាយៗខ្ញុំថាដូចវាល្អដែលភាសានេះអភិវឌ្ឍន៍ជនបទហ៊ុមព័ទ្ធទីក្រុង ចង់និយាយថាធ្វើម៉េចឲ្យជនបទ

មានផ្លូវ មានវិស័យសុខាភិបាល មានមន្ទីរពេទ្យ សាលារៀន ធ្វើម៉េចឲ្យប្រជាជនយើងដែលនៅជនបទ ដែលនៅដាច់ស្រយាលពីទីក្រុង ធ្វើម៉េចឲ្យវាមានជីវភាព មានការយល់ដឹងប្រហាក់ប្រហែលនឹងប្រជាជនដែលនៅទីក្រុងដែរ គឺសំណូមពរដល់អង្គការជាតិ និយាយរួមស្ថាប័នគ្រប់ស្ថាប័នទាំងអស់នៅក្នុងជាតិ ក៏ដូចអន្តរជាតិជួយរិះរកវិធីសាស្ត្រមធ្យោបាយអ្វីរូបមន្តអីដើម្បីធ្វើម៉េចឲ្យជាតិយើងវាមានការវិវត្តន៍ឈានឡើង ។

ដានី ៖ បាទ! អញ្ចឹងខ្ញុំអរគុណអ៊ំច្រើនដែលចំណាយពេលប្រហែលជាពីរម៉ោង ដែលឲ្យខ្ញុំដឹងពីជីវិតរបស់អ៊ំដែលរស់នៅក្នុងភូមិម៉ាឡៃ បាទអញ្ចឹងខ្ញុំអរគុណច្រើន ។

«ចប់»